

# ការសិក្សា

## ស្តីពី

## ក្របខ័ណ្ឌយុទ្ធសាស្ត្រ
## និងផែនការសកម្មភាពសម្រាប់ពង្រឹង
## សមត្ថភាពព្រឹទ្ធសភាកម្ពុជា
## (២០២១-២០៣០)

**ខែឧសភា ឆ្នាំ២០២០**

# អារម្ភកថា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានខិតខំដឹកនាំការសិក្សារួមមួយលើឯកសារស្តីពី **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជាសម្រាប់រយៈពេល១០ឆ្នាំ ទៅមុខទៀត** (**២០២១-២០៣០**) ដែលបានដាក់អនុវត្តតាំងពីឆ្នាំ២០១៤ និងដល់ពេលត្រូវធ្វើបច្ចុប្បន្នភាពដើម្បីបន្តអនុវត្តពីឆ្នាំ ២០២១ ដល់ឆ្នាំ២០៣០ ។

នេះគឺជាទស្សនទានអំពីចក្ខុវិស័យរយៈពេល១០ឆ្នាំខាងមុខរបស់ស្ថាប័នហើយក៏ជាឯកសារមូលដ្ឋានជាគន្លឹះផងដែរ សម្រាប់ការអភិវឌ្ឍស្ថាប័នតទៅអនាគតឲ្យបានប្រកបដោយចីរភាពក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជាបន្តដំណើរទៅមុខក្នុងសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ ប្រកបដោយកំណែទម្រង់ពហុវិស័យ ។

ការសាកល្បងសិក្សា ពិចារណាអំពីទិសដៅជាយុទ្ធសាស្ត្របានផ្តល់គំនិតក្នុងការរៀបចំតាក់តែងគោលបំណង នៃគោលនយោបាយដែលទាក់ទងដល់ការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ព្រមទាំងការរៀបចំនូវយុទ្ធសាស្ត្រអាទិភាពចម្បងចំនួន ៥ចំណុច ផ្តោតលើការពង្រឹងមុខងារព្រឹទ្ធសភាដែលត្រូវរំលេចផែនការសកម្មភាពដើម្បីឱ្យការអនុវត្តឲ្យបានសកម្ម ជាក់ស្តែង និងរស់រវើកនូវយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។ ក្នុងនោះការសិក្សានេះបានឆ្លុះបញ្ចាំងឲ្យឃើញអំពីហានិភ័យដែលអាចកើតមានផងដែរ ។

អនុលោមទៅតាមបរិបទ និងស្ថានភាពថ្មីនៃការវិវត្តរបស់ប្រទេសជាតិដែលកំពុងមានសន្តិភាព និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព សក្តានុពល

និងពន្ទឺថ្មីតម្រូវឲ្យយើងធ្វើការសិក្សាឲ្យបានគ្រប់ជ្រុងជ្រោយនូវគ្រប់ទិដ្ឋភាពនៃការវិវឌ្ឍឈានទៅឡើងរបស់ព្រឹទ្ធសភា ។

អគ្គលេខាធិការដ្ឋាន សូមរង់ចាំទទួលដោយសេចក្តីសោមនស្សរីករាយនូវគ្រប់យោបល់បំពេញបន្ថែម កែលម្អ ឬទិទៀនដោយស្ថាបនាពីគ្រប់មជ្ឈដ្ឋានទាំងអស់ ជាពិសេសពីសមាជិក សមាជិកាព្រឹទ្ធសភាដ៏ឧត្តុង្គឧត្តម ។

អគ្គលេខាធិការដ្ឋានសង្ឃឹមថា ក្រោយទទួលបាននូវគ្រប់មតិយោបល់និងអនុសាសន៍ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ឯកសារនេះនឹងមានគុណភាពមួយថ្មីដែលឆ្លើយតបទៅនឹងការរំពឹងទុកថ្មីដែលចង់បានសម្រាប់ដំណើរទៅកាន់វឌ្ឍនភាពពិតប្រាកដ ។

**ដោយអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់**
**អំពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០

# មាតិកា

## ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា ២០២១-២០៣០


I-**សេចក្តីផ្តើម** ............................................................................ ០១

II-**ដំណើរនៃការអភិវឌ្ឍព្រឹទ្ធសភា** ................................................ ០១

*១/-ផែនការសកម្មភាពរយៈពេលខ្លី (២០០៧-២០០៩)...........០៣*

*២/-ផែនការសកម្មភាពរយៈពេលមធ្យម (២០១០-២០១៣)...០៣*

*៣/-ផែនការសកម្មភាពរយៈពេលវែង (២០១៤-២០១៩)........០៤*

III-**ស្ថានភាពបច្ចុប្បន្នរបស់ព្រឹទ្ធសភាកម្ពុជា**.................................០៥

IV-**ការប្រឈមរបស់ព្រឹទ្ធសភា** ...................................................០៦

*១/-សាកលភាវូបនីយកម្ម ..........................................................០៦*

*២/-សមាហរណកម្មតំបន់ ........................................................០៧*

*៣/-វឌ្ឍនភាពឥតឈប់ឈរនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព័ត៌មាន..................................................................................០៧*

*៤/-លក្ខខណ្ឌផ្ទាល់នៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា តាមដំណាក់កាលនីមួយៗ ..............................................០៨*

*៥/-លក្ខខណ្ឌផ្ទាល់ពីការអភិវឌ្ឍរបស់ព្រឹទ្ធសភា ដែលទាមទារ នូវតម្រូវការ និងសំណូមពរថ្មីៗ ......................................០៨*

V-**ចក្ខុវិស័យរបស់ព្រឹទ្ធសភា** ........................................................០៩

*១-ភាពតំណាង ..........................................................................០៩*

២-តម្លាភាព..........................................................................១០
៣-ភាពចូលជិតបាន.................................................................១០
៤-គណនេយ្យភាព...................................................................១០
៥-ប្រសិទ្ធភាព........................................................................១០
VI-**គោលបំណងនៃគោលនយោបាយរបស់ព្រឹទ្ធសភា**.............១៣
**គោលបំណងគោលនយោបាយ** : ការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ លើមូលដ្ឋាននៃស្មារតីបង្រួបបង្រួមជាតិ និងសុខដុមកម្មជាតិទាំងមូល ក្រោមដំបូលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍយូរអង្វែង......................................................................................១៦
**១-យុទ្ធសាស្ត្រអាទិភាពទី១ : ការពង្រឹងពង្រីកមុខងារនីតិកម្ម**..........................១៧
**២-យុទ្ធសាស្ត្រអាទិភាពទី២ : ការពង្រឹងពង្រីកមុខងារតាមដានការអនុវត្តច្បាប់**.២៨
**៣-យុទ្ធសាស្ត្រអាទិភាពទី៣ : ការពង្រឹងពង្រីកមុខងារតំណាង**..........................៣២
-ការបង្កើនទំនាក់ទំនងសាធារណៈ និងបេសកកម្មជាប្រព័ន្ធទៅកាន់ភូមិភាគ និងមូលដ្ឋាន...................៣២
-ការពិគ្រោះយោបល់ជាសាធារណៈ និងវេទិកាសាធារណៈ.........................................................៣៣
**៤-យុទ្ធសាស្ត្រអាទិភាពទី៤ : ការពង្រឹងពង្រីកមុខងារសហប្រតិបត្តិការអន្តរជាតិ**.....៣៩
- សិទ្ធិមនុស្ស........................................................................៤៣

- សមភាពរវាងភេទ.........................................៤៣
- ការអភិវឌ្ឍ..................................................៤៤
- ពាណិជ្ជកម្ម..................................................៤៤
- ការចូលរួមរបស់សភានៅក្នុងដំណើរការសមាហរណកម្មតំបន់.........................................................៤៥
- ការទូតសភា...................................................៤៥
- សហប្រតិបត្តិការសភា......................................៤៦
- ការនួយខាងបច្ចេកទេសសភា..............................៤៧
**៥-យុទ្ធសាស្ត្រអាទិភាពទី៥ : ការពង្រឹងពង្រីកមុខងារអភិបាលស្ថាប័ន** .............៤៩
៥-១.ការអភិវឌ្ឍធនធានមនុស្ស ដើម្បីព្រឹទ្ធសភាមានសេវាគាំទ្រប្រកបដោយគុណភាព ...................៤៩
៥-២.ការអភិវឌ្ឍវិស័យទំនាក់ទំនងសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពរបស់ព្រឹទ្ធសភា................៥២
៥-៣.ការធានាគ្រប់គ្រងសន្តិសុខ សុវត្ថិភាពព្រឹទ្ធសភាឱ្យបានពេញលេញ និងការធានាបើកចំហព្រឹទ្ធសភាជាសាធារណៈឱ្យកាន់តែមានលក្ខណៈគាប់ប្រសើរ...៥៤
VII-**ហានិភ័យ** ..........................................................៥៥
VIII-**សេចក្តីសន្និដ្ឋាន** ....................................................៥៦

# ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព
# សម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា ២០២១-២០៣០

## I-សេចក្តីផ្តើម

ព្រឹទ្ធសភាកម្ពុជា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុង និងច្បាប់ជាធរមាន ។

ក្នុងរយៈពេល២១ឆ្នាំកន្លងទៅ (១៩៩៩-២០២០) ព្រឹទ្ធសភាកម្ពុជាបានខិតខំបំពេញនូវតួនាទីរបស់ខ្លួនរួមជាមួយរដ្ឋសភាក្នុងនាមអង្គការនីតិប្បញ្ញត្តិ ហើយទទួលបាននូវលទ្ធផលល្អជាជំហានៗ ក្នុងនីតិកាលទី១ នីតិកាលទី២ នីតិកាលទី៣ និងចូលមកដល់នីតិកាលទី៤ នេះៗ

ការគាំទ្រពីអង្គការនីតិប្បញ្ញត្តិនៃប្រទេសក្នុងតំបន់ និងលើពិភពលោក ជំនួយពីដៃគូអភិវឌ្ឍន៍សភា និងរដ្ឋាភិបាលនៃប្រទេសជាមិត្ត ព្រមទាំងពីអង្គការអន្តរជាតិជាដៃគូនានា រួមទាំងការខិតខំយ៉ាងខ្លាំងក្លាផ្ទាល់ខ្លួនផង ជំរុញឱ្យព្រឹទ្ធសភា និងអង្គការនីតិប្បញ្ញត្តិកម្ពុជាកសាង និងពង្រីកបាននូវសមត្ថភាពមួយកម្រិតទៀតនៅក្នុងដំណាក់កាលថ្មី នៃការធ្វើសមាហរណកម្មខ្លួនទៅក្នុងក្របខ័ណ្ឌអន្តរសភា ពហុភាគី តំបន់ និងពិភពលោក ព្រមទាំងមានទំនាក់ទំនងប្រកបដោយផ្លែផ្កាក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយអង្គការនីតិប្បញ្ញត្តិនៃប្រទេសជាមិត្តជិតឆ្ងាយ ។

## II-ដំណើរនៃការអភិវឌ្ឍព្រឹទ្ធសភា

ការអភិវឌ្ឍព្រឹទ្ធសភា បានស្ថិតក្រោមក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រចំនួនពីរគឺ ៖

១-ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (២០០៣-២០០៨)ៗ

២-ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០០៧-២០១៨)។

ព្រឹទ្ធសភាបានអនុវត្តប្រកបដោយផ្លែផ្កានូវផែនការយុទ្ធសាស្ត្រដំបូង (២០០៣-២០០៨) ដែលមានគោលដៅយុទ្ធសាស្ត្រចំនួន ៥ គឺ ៖

- គោលដៅយុទ្ធសាស្ត្រទី១ : ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស។
- គោលដៅយុទ្ធសាស្ត្រទី២ : រចនាសម្ព័ន្ធ ប្រព័ន្ធគោលនយោបាយ និងនីតិវិធី នៃការគ្រប់គ្រង ។
- គោលដៅយុទ្ធសាស្ត្រទី៣ : ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។
- គោលដៅយុទ្ធសាស្ត្រទី៤ : ការផ្សព្វផ្សាយព័ត៌មាន។
- គោលដៅយុទ្ធសាស្ត្រទី៥ : ទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

ផែនការយុទ្ធសាស្ត្រខាងលើនេះ បានក្រាលផ្លូវទៅដល់ការរៀបចំ និងដាក់អនុវត្តជាបន្តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០០៧-២០១៨) ដែលមានគោលដៅយុទ្ធសាស្ត្រចំនួន ៦ គឺ៖

- គោលដៅយុទ្ធសាស្ត្រទី១ : អង្គការនីតិប្បញ្ញត្តិដែលមានសមត្ថភាពពេញលេញក្នុងការធ្វើច្បាប់ ។
- គោលដៅយុទ្ធសាស្ត្រទី២ : អង្គការនីតិប្បញ្ញត្តិដែលមានសមត្ថភាពពេញលេញក្នុងការតាមដានស្ថាប័ននីតិប្រតិបត្តិ។
- គោលដៅយុទ្ធសាស្ត្រទី៣ : ស្ថាប័នដែលជាតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ពិតប្រាកដ ។

-គោលដៅយុទ្ធសាស្ត្រទី៤ : ព្រឹទ្ធសភាដែលមានប្រសិទ្ធភាពក្នុងការធានានូវលំហូរព័ត៌មាន ។

-គោលដៅយុទ្ធសាស្ត្រទី៥ : ព្រឹទ្ធសភាដែលមានសេវាគាំទ្រប្រកបដោយគុណភាព ។

-គោលដៅយុទ្ធសាស្ត្រទី៦ : ព្រឹទ្ធសភាដែលអនុវត្តទំនាក់ទំនងអន្តរជាតិប្រកបដោយកិត្យានុភាព ។

ស្របតាមគោលដៅយុទ្ធសាស្ត្រទាំង ៦ចំណុច ផែនការសកម្មភាពត្រូវបានរៀបចំសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដូចតទៅ ៖

**+ ផែនការសកម្មភាពរយៈពេលខ្លី (២០០៧-២០០៩)**

១-ការពង្រឹងតួនាទីរបស់ព្រឹទ្ធសភា

ក/-ការពង្រឹងតួនាទីធ្វើច្បាប់

ខ/-ការពង្រឹងតួនាទីតាមដានអង្គនីតិប្រតិបត្តិ

គ/-ការពង្រឹងតួនាទីតំណាង

ឃ/-ការពិនិត្យមើលនីតិវិធីពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តី ស្នើច្បាប់ ។

២-ការពង្រឹងធនធានមនុស្ស និងការអភិវឌ្ឍស្ថាប័ន

ក/-ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីព្រឹទ្ធសភា

ខ/-សំណូមពរជាយុទ្ធសាស្ត្រសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាពព្រឹទ្ធសភា ។

**+ ផែនការសកម្មភាពរយៈពេលមធ្យម (២០១០-២០១៣)**

១-ការបណ្តុះបណ្តាលសម្រាប់សមាជិកព្រឹទ្ធសភាថ្មី

២-ការពិនិត្យមើលនីតិវិធីពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

៣-ការចូលរួមរបស់សភានៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់តាំងពីដំណាក់កាលដំបូង

៤-ផែនការយុទ្ធសាស្ត្រថ្នាក់គណៈកម្មការនានា

៥-ការពង្រឹងតួនាទីរៀបចំ និងតាមដានថវិកា ព្រមទាំងតាមដានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងវប្បធម៌

៦-ការពង្រឹងទំនាក់ទំនងសាធារណៈ

៧-ភាពជាតំណាងរបស់ព្រឹទ្ធសភា

៨-កម្មវិធីបណ្តុះបណ្តាលសម្រាប់និស្សិត ។

**+ ផែនការសកម្មភាពរយៈពេលវែង (២០១៤-២០១៩)**

១-ការបង្កើតមជ្ឈមណ្ឌលសភា

២-ការបន្តពង្រឹងតួនាទីរៀបចំ និងតាមដានថវិកា និងការតាមដានការវិវត្តច្បាប់ សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន

៣-ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវរបស់ព្រឹទ្ធសភា

៤-ការធានាសមត្ថភាពធ្វើជាតំណាងរបស់សមាជិកព្រឹទ្ធសភា ។

+ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជារយៈពេល ១០ឆ្នាំ (២០២១-២០៣០) ដោយផ្តោតសំខាន់ទៅលើយុទ្ធសាស្ត្រអាទិភាពចំនួន ៥:

១-យុទ្ធសាស្ត្រអាទិភាពទី១ : ការពង្រឹងពង្រីកមុខងារនីតិកម្ម

២-យុទ្ធសាស្ត្រអាទិភាពទី២ : ការពង្រឹងពង្រីកមុខងារការតាមដានការអនុវត្តច្បាប់

៣-យុទ្ធសាស្ត្រអាទិភាពទី៣: ការពង្រឹងពង្រីកមុខងារតំណាង

៤-យុទ្ធសាស្ត្រអាទិភាពទី៤ : ការពង្រឹងពង្រីកមុខងារសហប្រតិ-
បត្តិការអន្តរជាតិ និងទំនាក់ទំនង
សាធារណៈ

៥-យុទ្ធសាស្ត្រអាទិភាពទី៥ : ការពង្រឹងពង្រីកមុខងារអភិវឌ្ឍន៍
ស្ថាប័ន

លើមូលដ្ឋាននៃឯកសារគោលទាំងពីរសម្រាប់ការតម្រង់ទិស ព្រឹទ្ធសភាបានខិតខំអភិវឌ្ឍស្ថាប័នប្រកបដោយសក្ដានុពលក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងបានធ្វើដំណើររីកចម្រើនទៅមុខយ៉ាងឆាប់រហ័សលើចំណុចជាច្រើនជាងអ្វីដែលបានគ្រោងទុក ។ ប៉ុន្តែក៏នៅមានខ្វះចន្លោះជាច្រើនប្រការដែលចាំបាច់ត្រូវគិតគូរពិចារណា និងធ្វើបច្ចុប្បន្នភាពឱ្យបានទាន់ពេលវេលា ។

## III-ស្ថានភាពបច្ចុប្បន្នរបស់ព្រឹទ្ធសភាកម្ពុជា

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានាឆ្នាំ២០០៦ ឆ្នាំ២០១២ និងឆ្នាំ២០១៨ ការរៀបចំបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាថ្មីឡើងវិញតាមនីតិកាលនីមួយៗ ការកសាងបាននូវច្បាប់ស្ដីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា, ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា, ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ, ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា(លើកទី២) រួមទាំងការធ្វើស្វ័យវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យរបស់សហភាពអន្តរសភា(IPU) បានធ្វើឱ្យតួនាទីរបស់ព្រឹទ្ធសភា ត្រូវបានលើកតម្កើងឱ្យទូលំទូលាយក្នុងមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ។ សមាជិកព្រឹទ្ធសភាបានក្លាយទៅជាតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៨ភូមិភាគ និងជាតំណាងឱ្យប្រជាជាតិខ្មែរទាំងមូល ។

សមាជិកព្រឹទ្ធសភាបានផ្សារភ្ជាប់សកម្មភាពទៅនឹងតថភាពរបស់ថ្នាក់ក្រោមជាតិដែលកំពុងចូលរួមអនុវត្តយ៉ាងសកម្មនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

ការរៀបចំដំណើរការយន្តការ "ក្រុម" ដូចជាក្រុមសមាជិកព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ ក្រុមសមាជិកាព្រឹទ្ធសភា ក្រុមមិត្តភាព ក្រុមទទួលបន្ទុកការងារអន្តរសភា APF, AIPA, IPU, APPF, APA, CLV និងក្រុមមិត្តភាពផ្សេងៗទៀតចំនួន១៤...។ល។ ព្រមទាំងការរៀបចំវេទិកាច្រើនកម្រិតនៅថ្នាក់ក្រោមជាតិបានធ្វើឱ្យការបំពេញមុខងារទាំងបីរបស់ព្រឹទ្ធសភាបាននឹងកំពុងប្រែប្រួលទាំងបរិមាណ និងគុណភាព ។ ស្របតាមការវិវត្តរបស់ព្រឹទ្ធសភានេះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួន។ ពិសេសសម្រាប់ការវិវត្តលើវិស័យគ្រប់គ្រងហិរញ្ញវត្ថុ និងថវិការដ្ឋ ព្រឹទ្ធសភាបានរៀបចំកញ្ចប់ថវិកាតាមកម្មវិធីប្រចាំឆ្នាំសម្រាប់ផ្តល់ជូនរចនាសម្ព័ន្ធនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាលអនុវត្តក្នុងនាមជាអង្គភាពថវិកា ដែលត្រូវអនុវត្តថវិកាទៀងទាត់តាមកម្មវិធី ។

## IV-ការប្រឈមរបស់ព្រឹទ្ធសភា

វឌ្ឍនភាពផ្ទៃក្នុង រួមទាំងលទ្ធផលនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីក្នុងកម្រិតតំបន់ និងអន្តរជាតិ ប្រកបដោយផ្លែផ្កាបានផ្តល់ផលអនុគ្រោះចំពោះដំណើរទៅមុខរបស់ព្រឹទ្ធសភា ។

លើការជាក់ស្តែង ក្នុងរយៈពេលវែង ព្រឹទ្ធសភាត្រូវបន្តប្រឈមនឹងលក្ខខណ្ឌ និងបរិយាកាសធំៗដូចតទៅ ៖

**១/- សាកលភាវូបនីយកម្ម** : ដំណើរការសាកលភាវូបនីយកម្ម តម្រូវឱ្យអង្គនីតិប្បញ្ញត្តិកម្ពុជាខិតខំដើរតាមស្តង់ដារការងារជាលក្ខន្តិកៈនៃសភាទំនើបក្នុងក្របខ័ណ្ឌពិភពលោក ។

**២/- សមាហរណកម្មតំបន់** : ក្នុងនាមជាសមាជិកសហគមន៍អាស៊ាន ចាប់ពីឆ្នាំ២០១៥មក តម្រូវឱ្យមានកិច្ចសហប្រតិបត្តិការជាចម្បងរវាងសភានៃប្រទេសអាស៊ានលើការងារនីតិកម្ម ជាពិសេសរវាងនីតិកម្មតំបន់ និងនីតិកម្មជាតិ ដែលត្រូវឯកភាព និងឆ្លើយឆ្លងស៊ីសង្វាក់គ្នាជាប្រព័ន្ធឯកភាព។ អន្តរកម្មរវាងសភាកាន់តែទូលំទូលាយ ដើម្បីបម្រើបុព្វហេតុសហគមន៍អាស៊ានខាងនយោបាយ និងសន្តិសុខ សហគមន៍អាស៊ានខាងសេដ្ឋកិច្ច និងសហគមន៍អាស៊ានខាងសង្គម និងវប្បធម៌។ការយល់ដឹងអំពីអាស៊ាន ចំណេះដឹងភាសាបរទេស និងជំនាញសមស្របរបស់មន្ត្រីសម្រាប់បម្រើដល់កិច្ចសហប្រតិបត្តិការរវាងសភាក្នុងក្របខ័ណ្ឌអាស៊ាននៅមានកម្រិត មិនទាន់អាចឆ្លើយតបបានទាំងស្រុងទៅនឹងបរិបទអាស៊ានសម្រាប់ពេលបច្ចុប្បន្ន និងទៅអនាគត ។

**៣/-វឌ្ឍនភាពឥតឈប់ឈរនៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាន** : សភាភាគច្រើននៅលើពិភពលោកបានច្នៃប្រឌិតបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដោយទូលំទូលាយនៅក្នុងការងារប្រចាំថ្ងៃ ជាពិសេស ការអនុវត្តមុខងារចម្បងទាំងបីរបស់ស្ថាប័ន។ ឯអង្គនីតិបញ្ញត្តិកម្ពុជាយើងស្ថិតក្នុងដំណាក់កាលដំបូង ទើបតែចាប់ផ្តើមប្រើប្រាស់បច្ចេក វិទ្យាព័ត៌មាន និងជាពិសេសប្រើប្រាស់ IPad ក្នុងព្រឹទ្ធសភាដោយពុំទាន់បានស៊ីជម្រៅ ទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាពជាប្រព័ន្ធនៅឡើយ ។

-ការប្រតិបត្តិការងារតាមប្រព័ន្ធ បច្ចេកវិទ្យាព័ត៌មានសម្រាប់ការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គ វេទិកាតាមភូមិភាគ

សិក្ខាសាលា និងការងាររដ្ឋបាលពីចម្ងាយក្នុងគ្រាមានអាសន្នពុំទាន់បានក្លាយ ជាទម្លាប់ប្រតិប...លំទូលាយនៅឡើយ ។

**៧-លក្ខខណ្ឌផ្ទាល់នៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានកម្ពុជាតាមដំណាក់កាលនីមួយៗ**: កំណែទម្រង់លើវិស័យសំខាន់ៗរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា និងឆន្ទៈរបស់រាជរដ្ឋាភិបាលប្រឆាំងប្តូរផ្តាច់នឹងបាតុភាពអវិជ្ជមាន និងអសកម្មសព្វសារពើនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន មានទំនាក់ទំនងពាក់ព័ន្ធនឹងដំណើរការជារួមរបស់អង្គនីតិប្បញ្ញត្តិកម្ពុជា ក្នុងប្រតិបត្តិការលើមុខងារស្នូលទាំងបីប្រកបដោយការទទួលខុសត្រូវ និងក្នុងគុណភាពមួយថ្មី ដែលឈរលើនីតិរដ្ឋ និងអភិបាលកិច្ចល្អ ។

**៨-លក្ខខណ្ឌផ្ទាល់ពីការអភិវឌ្ឍរបស់ព្រឹទ្ធសភា ដែលទាមទារនូវតម្រូវការ និងសំណូមពរថ្មីៗ** : នីតិវិធី ស្តង់ដារ ធនធាន ប្រព័ន្ធការងារ ប្រព័ន្ធសន្តិសុខ សុវត្ថិភាព ប្រព័ន្ធបច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសទាមទារឱ្យកាន់តែល្អប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងទំហំការងារ និងការទទួលខុសត្រូវចំពោះមុខសាធារណជន ។ អ្វីៗនៅមានកម្រិតអាស្រ័យដោយធនធាន សមត្ថភាព និងសេវាគាំទ្រសព្វប្រ ភេទនៅតែត្រូវខិតខំបំពេញបន្ថែមឱ្យកាន់តែខ្ពស់ថែមទៀត ជាអាទិ៍ នីតិវិធីខ្លះពុំទាន់មានទម្លាប់ធ្វើជាប្រព័ន្ធនៅឡើយ (ការស្រាវជ្រាវ និងការពិគ្រោះយោបល់) ។ នីតិវិធីគួរត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យចេញជារូបរាងពិតប្រាកដសម្រាប់ការអនុវត្តមាត្រានីមួយៗនៃរដ្ឋធម្មនុញ្ញ ពាក់ព័ន្ធនឹងតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា និងប្រការនីមួយៗនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធ-សភា ។ ការងារវិមជ្ឈការ និងវិសហមជ្ឈការដែលរដ្ឋបានអនុវត្តតាំងពី

ឆ្នាំ២០០២មក កំពុងប្រព្រឹត្តទៅទន្ទឹមនឹងការបន្តកសាងច្បាប់ បទដ្ឋានការផ្ទេរសមត្ថកិច្ច ធនធាន មធ្យោបាយ និងការរៀបចំក្របខ័ណ្ឌមន្ត្រីរាជការសម្រាប់បម្រើការនៅថ្នាក់ក្រោមជាតិ ជាពិសេសការសម្រិតសម្រាំងលើការផ្តល់សេវាបម្រើប្រជាពលរដ្ឋឱ្យបានល្អប្រសើរ និងការកសាងជំនឿ និងទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋអំណាចគ្រប់ជាន់ថ្នាក់ និងរាជរដ្ឋាភិបាល ។

ព្រឹទ្ធសភា បានចូលរួមដោះស្រាយពាក្យបណ្តឹងតវ៉ាមួយចំនួនរបស់ប្រជាពលរដ្ឋ។ ប៉ុន្តែទាំងនីតិវិធី និងប្រសិទ្ធភាពជាទូទៅពុំទាន់ជានាបានល្អជាប្រចាំនៅឡើយ ។

ព្រឹទ្ធសភាត្រូវការនូវធាតុចូលនិងការវិនិយោគជាច្រើនទៀតលើគ្រប់វិស័យ ដើម្បីឈានឆ្ពោះទៅកាន់លក្ខន្តិកៈជាសភាទំនើប នាសតវត្សទី២១ នេះ។

## V-ចក្ខុវិស័យរបស់ព្រឹទ្ធសភា

ក្នុងស្ថានភាពថ្មីនេះ ព្រឹទ្ធសភាកម្ពុជាបានមើលឃើញថា ព្រឹទ្ធសភាបានវិវត្តដល់ដំណាក់កាលមួយថ្មីដែលត្រូវប្រែប្រួលយុទ្ធសាស្ត្រ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារស្នូលទាំងបីរបស់ខ្លួនគឺ មុខងារនីតិកម្ម (ធ្វើច្បាប់) មុខងារត្រួតពិនិត្យ (តាមដានការអនុវត្តច្បាប់) និងមុខងារតំណាង ។ ព្រឹទ្ធសភាត្រូវខិតខំពង្រឹងពង្រីកសកម្មភាពឆ្ពោះទៅអនុវត្តការងារជាប្រព័ន្ធនៃសភាទំនើប ដោយត្រូវឈរលើលក្ខណៈវិនិច្ឆ័យដូចតទៅ៖

**១- ភាពតំណាង** : ខាងសង្គម និងនយោបាយប្រកបដោយបរិយាប័ន្នរបស់ប្រជាជាតិទាំងមូល ដែលចម្រុះគ្នា ហើយធានាដល់ភាពតំណាងដោយស្មើភាពគ្នា និងដោយតុល្យភាពខាងយេនឌ័រសម្រាប់សមាជិកព្រឹទ្ធសភាទាំងអស់។

**២- តម្លាភាព** : ដោយបើកចំហទំនាក់ទំនងចំពោះប្រជាពលរដ្ឋទាំងអស់ តាមរយៈប្រព័ន្ធព័ត៌មាន និងបណ្តាញសង្គម និងមាន តម្លាភាពនៅក្នុងការចាត់ចែងកិច្ចការសព្វសារពើរបស់ ព្រឹទ្ធសភា ។

**៣- ភាពចូលជិតបាន** : ដោយលើកទឹកចិត្តឱ្យប្រជាពលរដ្ឋ ជាពិសេស សាធារណជន យុវជន កុមារ សមាគម អង្គការមិនមែន រដ្ឋាភិបាល និងវិស័យឯកជនអាចចូលរួមបានក្នុង ដំណើរការការងាររបស់សភា ។

**៤- គណនេយ្យភាព**: សមាជិកព្រឹទ្ធសភាត្រូវរាយការណ៍ដោយទៀងទាត់ ឱ្យម្ចាស់ឆ្នោតបានដឹង អំពីរបៀប និងលទ្ធផលដែលខ្លួន បំពេញអាណត្តិរបស់ខ្លួនដើម្បីបម្រើផលប្រយោជន៍ របស់ប្រជាពលរដ្ឋ និងប្រទេសជាតិ និងអំពីសុចរិតភាព ជាឧត្តមគតិ និងឆន្ទៈប្តូរផ្តាច់របស់ខ្លួន ។

**៥- ប្រសិទ្ធភាព** : ការចាត់តាំងត្រូវស្របតាមគុណតម្លៃប្រជាធិបតេយ្យ ហើយបំពេញបានល្អនូវមុខងារនីតិកម្ម តំណាង និង ត្រួតពិនិត្យរបស់សភា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវ ការរបស់ប្រជាពលរដ្ឋទាំងមូល ។

សម្រាប់រយៈពេលខាងមុខ ព្រឹទ្ធសភាមានចក្ខុវិស័យ គឺចង់ធ្វើឱ្យការអនុវត្ត ការងារសព្វសារពើរបស់ខ្លួនបានស្របតាមស្តង់ដារការងារនៃសភាទំនើប និង ជាដៃគូដ៏ល្អជាមួយសភានានាក្នុងតំបន់ និងពិភពលោកដោយ ៖

-ព្រឹទ្ធសភាបំពេញបាននូវមុខងារជាចម្បងជាតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងប្រទេស និងជាកម្លាំងចលករ ដើម្បីជានាជោគជ័យនៃការអនុវត្ត

គោលនយោបាយវិមជ្ឈការ វិសហមជ្ឈការរបស់រដ្ឋ និងការអភិវឌ្ឍឃុំ សង្កាត់ ថ្នាក់ក្រោមជាតិលើគ្រប់វិស័យ

-ព្រឹទ្ធសភាសម្រេចបាននូវមុខងារស្នូលទាំងបី : នីតិកម្ម តាមដានការអនុវត្តច្បាប់ និងតំណាងព្រមទាំងមុខងារគាំទ្រទាំងពីរៈមុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន ប្រកបដោយប្រសិទ្ធភាព និងគុណភាពជាទំនុកចិត្ត និងបង្អែករបស់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈជនជាតិ គ្រប់វិស័យ និងគ្រប់មជ្ឈដ្ឋាន

-គណៈកម្មការនានារបស់ព្រឹទ្ធសភា សម្រេចបាននូវមុខងារស្នូលទាំងបី៖ នីតិកម្ម ត្រួតពិនិត្យ និងព័ត៌មានក្នុងឋានៈជាកូនព្រឹទ្ធសភា (Mini-Senate) ពិតប្រាកដ ។

-ក្រុមសមាជិកព្រឹទ្ធសភានានា និងក្រុមសមាជិកាព្រឹទ្ធសភាក្លាយជាយន្តការដ៏សកម្ម រស់រវើក និងផ្លែផ្កានៃជីវិតប្រជាធិបតេយ្យនៅក្នុងព្រឹទ្ធសភា ។

-អគ្គលេខាធិការដ្ឋាន មានសមត្ថភាពផ្តល់សេវាបានល្អប្រសើរពេញលេញលើគ្រប់វិស័យ និងគ្រប់ជំនាញចាំបាច់ជាតម្រូវការរបស់ព្រឹទ្ធសភា គណៈកម្មការ ក្រុមនានារបស់ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាតាមប្រព័ន្ធរដ្ឋបាលនៃសភាទំនើប ដែលបំពាក់ដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាន់សម័យ និងធានាមានសន្តិសុខ សុវត្ថិភាព និងផាសុខភាពពេញលេញ ។

-មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន មានឆន្ទៈ និងការទទួលខុសត្រូវខ្ពស់ មានចំណេះដឹងទូលំទូលាយខាងវប្បធម៌នយោបាយ វប្បធម៌រដ្ឋបាល វប្បធម៌សភា វប្បធម៌ប្រជាធិបតេយ្យ វប្បធម៌នីតិរដ្ឋ

វប្បធម៌ជាតិ និងជំនាញគ្រប់ប្រភេទចាំបាច់សម្រាប់កិច្ចការសភា និងមានសមត្ថភាពភាសាខ្ពស់ ដែលអាចផ្តល់សេវាចាំបាច់ទាំង ស្រាវជ្រាវ សរសេរ និយាយ និងបកប្រែប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

ដើម្បីឱ្យចក្ខុវិស័យខាងលើនេះ អាចចេញបានជាលទ្ធផលពិតប្រាកដ និង

ដោយសក្តានុពល ទាំងរដ្ឋបាល ធនធាន បច្ចេកទេស នីតិវិធី បច្ចេកវិទ្យា ការស្រាវជ្រាវ និង ផ្តល់យោបល់ ។

ព្រឹទ្ធសភាសម្លឹងមើលទៅមុខក្នុងសុទិដ្ឋិនិយម ដោយសង្ឃឹមថា នឹងបន្តពង្រឹងពង្រីកឱ្យបានពេញលេញ និងជានិរន្តរនូវកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងសកម្ម និងទូលំទូលាយក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រខាងលើនេះ ឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានកម្ពុជាក្នុងដំណាក់កាលថ្មី ដែលឈរលើមូលដ្ឋាននៃការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ ដែលត្រូវមានកំណែទម្រង់ និងអភិបាលកិច្ចល្អជាស្នូលលើគ្រប់វិស័យ ។ គោលការណ៍ និងផែនការសកម្មភាពទាំងឡាយ ដែលបម្រើឱ្យយុទ្ធសាស្ត្រនេះ មានលក្ខណៈបើកទូលាយ និងឈានទៅធ្វើទំនើបកម្មព្រឹទ្ធសភាកម្ពុជា ដើម្បីធ្វើឱ្យព្រឹទ្ធសភាកាន់តែរឹងមាំ និងមានសមត្ថភាពរ៉ាប់រងបានទាំងស្រុងនូវនិរន្តរភាពនៃដំណើរការគ្រប់ផ្នែក គ្រប់វិស័យរបស់ខ្លួន ទាំងនីតិវិធី បទដ្ឋាន រដ្ឋបាល ធនធាន បច្ចេកទេស បច្ចេកវិទ្យាព័ត៌មាន និងសន្តិសុខ សុវត្ថិភាព ផាសុខភាព ។

ជាមួយគ្នានោះ ព្រឹទ្ធសភាត្រូវខិតខំកសាងសមត្ថភាព ដើម្បីជាសេនាធិការមួយរបស់ជាតិ ក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការគោរពច្បាប់ និងសិទ្ធិមនុស្ស និងកំណែទម្រង់ពហុវិស័យ ពិសេសការអនុវត្តគោល

នយោបាយវិមជ្ឈការ វិសហមជ្ឈការ ហើយជាបង្អែកដ៏រឹងមាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស ដើម្បីការអភិវឌ្ឍខាងនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថានរបស់មូលដ្ឋាន និងថ្នាក់ក្រោមជាតិប្រកបដោយសក្តានុពល និង និរន្តរភាព ។ ជាក់ស្តែង ព្រឹទ្ធសភាត្រូវចូលរួមជំរុញការអនុវត្តគោលដៅអភិវឌ្ឍ ប្រកបដោយនិរន្តរភាពរបស់កម្ពុជា និងការពង្រឹងពង្រីកតួនាទីរបស់កម្ពុជាក្នុង សហគមន៍អាស៊ាន និងពិភពលោកក្នុងក្របខ័ណ្ឌនៃសាកលភាវូបនីយកម្ម និង ពហុភាគីនិយមដែលជាចរន្តនាំមុខហើយដែលកំពុងប្រឈមនឹងភាពស្មុគ្រស្មាញ មិនទៀងទាត់នាយុគសម័យនេះ ។

## VI-គោលបំណងនៃគោលនយោបាយរបស់ព្រឹទ្ធសភា

ការពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា គឺជាកត្តាស្នូលសម្រាប់រួមចំណែក ធ្វើឱ្យកិច្ចការនីតិបញ្ញត្តិរបស់ជាតិទទួលបានជោគជ័យជាការពង្រឹងពង្រីក ដំណើរឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នីតិរដ្ឋ អភិបាលកិច្ចល្អ ក្នុងក្របខ័ណ្ឌនៃផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមរបស់រាជរដ្ឋាភិបាលប្រកប ដោយបរិយាប័ន្ន ព្រមទាំងការអនុវត្តសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ថ្មីប្រកបដោយនិរន្តរភាព និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍ អាស៊ាន និងពិភពលោកដោយរលូន និងផ្លែផ្កា ។

ព្រឹទ្ធសភាត្រូវតែបង្កើនសមត្ថភាពរបស់ខ្លួន ដើម្បីធានាដល់ការបំពេញ តួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នីតិរដ្ឋ អភិបាលកិច្ចល្អ ការអនុវត្តកំណែទម្រង់ បន្តនិរន្តរភាពកំណើនសេដ្ឋកិច្ច និងការងារ លើកតម្កើងយុត្តិធម៌សង្គម ការគោរពសិទ្ធិមនុស្ស យេនឌ័រ រួមចំណែក ក្នុងការលើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ និងជំរុញការ អភិវឌ្ឍគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្សនៅថ្នាក់ក្រោមជាតិ ។

ម្យ៉ាងវិញទៀត ដើម្បីរួមចំណែកក្នុងការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ ព្រឹទ្ធសភាកម្ពុជាត្រូវឱ្យសច្ចាប័ន និងតាមដានមើលការអនុវត្តសន្ធិសញ្ញា អនុសញ្ញា ពិធីសារ និងកតិកាសញ្ញាអន្តរជាតិសំខាន់ៗ ។ កម្ពុជាត្រូវតាំងខ្លួនជាសមាជិកដ៏ល្អរបស់សហគមន៍អាស៊ាន អង្គការសហប្រជាជាតិ អង្គការពាណិជ្ជកម្មពិភពលោក និងជាហត្ថលេខីទទួលខុសត្រូវលើកិច្ចព្រមព្រៀង ពិធីសារ សន្ធិសញ្ញា អនុសញ្ញា អន្តរជាតិនានា។ ជាពិសេស ព្រឹទ្ធសភាត្រូវរួមចំណែកដើម្បីធានាថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សបានល្អ និងរលូន ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី សិទ្ធិកុមារ និងបរិស្ថានផងដែរ ។

ដោយមានកិច្ចសហការដោយរលូនល្អជាមួយអង្គនីតិប្រតិបត្តិក៏ដូចជាអង្គតុលាការ ព្រឹទ្ធសភាត្រូវពង្រឹងសមត្ថភាពឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត និងត្រូវគោរពតាមគោលការណ៍ ស្តីពីការបែងចែកអំណាចរដ្ឋឱ្យបានគាប់ប្រសើរ។ ចំពោះការប្រើប្រាស់អំណាចនីតិប្បញ្ញត្តិ ព្រឹទ្ធសភាត្រូវតែមានការឯកភាពកំណត់ និងបែងចែកតួនាទី ភារកិច្ច សមត្ថកិច្ច ដោយគិតដល់ទំនាក់ទំនងជាអចិន្ត្រៃយ៍រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងវិសាលភាព ទម្រង់ រូបភាព ខ្លឹមសារ ឧបករណ៍ និងធនធានចាំបាច់ឱ្យបានច្បាស់លាស់ជាមុនសម្រាប់បម្រើមុខងារទាំងប្រាំឱ្យបានពេញលេញ និងផ្លែផ្កាពិតប្រាកដ ។ ជាពិសេស ត្រូវធានាថា ប្រជាពលរដ្ឋអាចប្រើប្រាស់អំណាចរបស់ខ្លួនតាមរយៈព្រឹទ្ធសភាប្រកបដោយគុណភាពផងដែរ ។

ការកិច្ចរបស់ព្រឹទ្ធសភា ក្នុងការសម្របសម្រួលរវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ក៏ដូចជាការបែងចែកសិទ្ធិអំណាចក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការ ក្រុមនានា និងយន្តការផ្សេងទៀតក្នុងព្រឹទ្ធសភា គប្បីពិចារណា និងចែងដោយច្បាស់លាស់ក្នុងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ទន្ទឹមនោះត្រូវចង្អុលបង្ហាញ អំពីនីតិវិធីអនុវត្តដោយជាក់លាក់ ដើម្បីពង្រឹងពង្រីកការបង្រួបបង្រួមជាតិ និងបញ្ចៀសឱ្យបានជាស្ថាពរនូវវិបត្តិនយោបាយ ឬការជាប់គាំងសិប្បនិម្មិតផ្សេងៗ អាស្រ័យដោយការប្រកួតប្រជែងគ្នាខាងនយោបាយនៅក្រោយការបោះឆ្នោតនីមួយៗ ។

ការប្រើប្រាស់តួនាទីរបស់ក្រុមសមាជិកព្រឹទ្ធសភា ក្នុងលក្ខន្តិកៈច្បាស់លាស់ពិតប្រាកដ ដើម្បីញ៉ាំងឱ្យការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងស្តង់ដារការងារជាលក្ខណៈវិនិច្ឆ័យនៃសភាទំនើប បានក្លាយទៅជាការជាក់ស្តែងដែលរួមវិភាគទានដល់ការអភិវឌ្ឍព្រឹទ្ធសភាឱ្យបោះមួយជំហានដ៏សំខាន់ទៅមុខទៀត ។ ការផ្តល់សេវាស្រាវជ្រាវ ធនធាន មធ្យោបាយ បច្ចេកទេស បច្ចេកវិទ្យាឯកទេស និងទីកន្លែង ព្រមទាំងការគាំទ្រដល់ក្រុមសមាជិកព្រឹទ្ធសភានឹងធ្វើឱ្យការអនុវត្តនូវមុខងារទាំងប្រាំ និងការពិភាក្សាក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភាមានគុណភាព និងប្រសិទ្ធភាពមួយថ្មី ដែលពុំធ្លាប់មានពីមុនមកក្នុងប្រវត្តិសាស្ត្រនៃអង្គនីតិបញ្ញត្តិកម្ពុជា ។ នោះគឺជាការធានាបន្ថែមទៀត ដល់ការគោរពនូវសិទ្ធិរបស់ក្រុមភាគតិច និងក្រុមភាគច្រើន (ភាគច្រើនស្តាប់យោបល់របស់ភាគតិច ហើយភាគតិចត្រូវគោរពភាគច្រើន) នឹងធ្វើឱ្យជញ្ជីងនៃអំណាចកាន់តែមានតុល្យភាពក្នុងព្រឹទ្ធសភា ។ ក្រុមភាគច្រើន និងក្រុមភាគតិចត្រូវមានសិល្បៈនៃការសម្របសម្រួល និងសម្រុះសម្រួលទស្សនៈគ្នាទៅវិញទៅមកដោយទន់ភ្លន់ លើមូលដ្ឋាននៃការគោរពគ្នា ស្តាប់គ្នា និងផ្តល់តម្លៃគ្នាទៅវិញទៅមក ។

គ្រប់បញ្ហាសុទ្ធតែអាចដោះស្រាយបាន ដោយឈរលើការខិតខំពិភាក្សាដើម្បីស្វែងរក៖

-ការឯកភាពស្រុះស្រួលគ្នាទាំងស្រុង (Compromize) ដោយមានសម្បទានទៅវិញទៅមក

-ឬការឯកភាពស្របមតិគ្នា (Consensus) ក្រោយពីការខិតខំពិភាក្សារួមគ្នាកំណត់យកគោលជំហររួមមួយដូចគ្នា ។ ប្រការនេះអាចបញ្ចៀសបាននូវភាពមិនរលូន និងភាពរលាក់ក្នុងដំណើរការដាក់ស្តែងរបស់សភា ទំនាក់ទំនងរវាងគណបក្សនយោបាយ និងតួអង្គអ្នកនយោបាយ ។

វប្បធម៌នៃការរួមគ្នាស្វែងរកការស្រុះស្រួលគ្នា និងការស្របមតិគ្នា គឺជាការបង្កើនសុខដុមកម្មនៅក្នុងអង្គការនីតិបញ្ញត្តិជាតិនិងសង្គមជាតិទាំងមូល។ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រឹទ្ធសភាមានគោលបំណងគោលនយោបាយ និងកម្មវិធី ឬយុទ្ធសាស្ត្រជាអាទិភាពដូចខាងក្រោម ៖

**គោលបំណងគោលនយោបាយ** : **ការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ លើមូលដ្ឋាននៃស្មារតីបង្រួបបង្រួមជាតិ និងសុខដុមកម្មជាតិទាំងមូល ក្រោមដំបូលរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍយូរអង្វែង**

គោលបំណងគោលនយោបាយនេះ គឺសំដៅធ្វើឱ្យព្រឹទ្ធសភារួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើនបានឆាប់រហ័ស លើមូលដ្ឋាននៃការឯកភាពគ្នាលើការគ្រប់គ្រងរដ្ឋ គ្រប់គ្រងសង្គម គ្រប់គ្រងសេដ្ឋកិច្ច ក្នុងគុណភាព

និងប្រសិទ្ធភាពមួយថ្មី សមស្របតាមជំហានរីកចម្រើនរួមក្នុងក្របខ័ណ្ឌផ្ទៃក្នុងជាតិផ្ទាល់របស់កម្ពុជា សហគមន៍អាស៊ាន និងពិភពលោក។ ព្រឹទ្ធសភាត្រូវដាក់ចេញនូវយុទ្ធសាស្ត្រជាអាទិភាពចំនួន ៥សំខាន់ៗ ដូចខាងក្រោម ៖

**១-យុទ្ធសាស្ត្រអាទិភាពទី១ : ការពង្រឹងពង្រីកមុខងារនីតិកម្ម**

- ព្រឹទ្ធសភាត្រូវបង្ហាញនូវសមត្ថភាពគ្រប់គ្រាន់ ក្នុងការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីញ៉ាំងឱ្យប្រព័ន្ធច្បាប់ របស់ជាតិកាន់តែល្អ គ្រប់ជ្រុងជ្រោយ និងរលូន។ ព្រឹទ្ធសភាត្រូវបង្ហាញនូវចរិតជំនាញកាន់តែខ្ពស់ក្នុងការអនុវត្តមុខងារធ្វើច្បាប់ ដោយផ្អែកលើភាពចាស់ទុំ និងការថ្លឹងថ្លែងគ្រប់គ្រាន់ លើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវសភា និងការសិក្សាផលប៉ះពាល់RIAឱ្យបានហ្មត់ចត់អំពីឱកាស ភាពសមស្រប ភាពរលូន តម្លៃផលប៉ះពាល់ និងធនធានគ្រប់គ្រាន់ដើម្បីធានាការផ្សព្វផ្សាយ និងអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

-ព្រឹទ្ធសភាត្រូវធានាមានពេលវេលាគ្រប់គ្រាន់តាមការកំណត់ក្នុងរដ្ឋធម្មនុញ្ញអំពីរយៈពេលមួយខែយ៉ាងយូរក្នុងការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដោយត្រូវខិតខំចៀសវាងនូវប្រើប្រាស់នីតិវិធីប្រញាប់ (រយៈពេល៥ថ្ងៃ) ជាញឹកញាប់ ។ ព្រឹទ្ធសភាអាចបំពេញមុខងារនីតិកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព កិត្យានុភាព និងគ្រប់ជ្រុងជ្រោយ ប្រសិនបើមានឱកាសអនុវត្តន៍ទៀងទាត់នូវនីតិវិធីពិគ្រោះយោបល់ជាសាធារណៈ និងឈរលើការស្រាវជ្រាវសភា និងការសិក្សាផលប៉ះពាល់RIA មួយដែលច្បាស់លាស់ និងទៀងទាត់ ជាបង្អែកពិតប្រាកដ ។

-គណៈកម្មការនានារបស់ព្រឹទ្ធសភា ត្រូវមានបន្ទុកក្នុងការពិនិត្យ សិក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានបញ្ជូនមក ស្របតាមការប្រគល់ភារកិច្ចពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។ ក្នុងករណីដែលសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ពាក់ព័ន្ធវិស័យជាសមត្ថកិច្ចគណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍អាចប្រគល់ភារកិច្ចជូនគណៈកម្មការច្រើនរួមគ្នាពិនិត្យសិក្សា ប៉ុន្តែត្រូវឱ្យគណៈកម្មការមួយទទួលបន្ទុកធ្វើរបាយការណ៍ ឬអាចបង្កើតជាគណៈកម្មការពិសេស ឬគណៈកម្មការចំពោះកិច្ចសម្រាប់ពិនិត្យសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬក៏បញ្ហាអាទិភាពចាំបាច់ចំពោះមុខណាមួយរបស់ស្ថាប័ន ។

-គណៈកម្មការនានាត្រូវចាប់ផ្ដើមមានទម្លាប់ និងរបបរៀបចំសវនាការពិគ្រោះយោបល់ក្នុងដំណើរការពិនិត្យសេចក្ដីព្រាងច្បាប់ ឬព្រាងសេចក្ដីស្នើច្បាប់ ហើយត្រូវទទួលបានព័ត៌មានគ្រប់គ្រាន់ពីអ្នកជំនាញ ពីអ្នកអនុវត្ត ពីសង្គមស៊ីវិល ពីវិស័យឯកជន ពីម្ចាស់ឆ្នោត ឬពីប្រជាពលរដ្ឋដោយផ្ទាល់ ។

-សមាជិកព្រឹទ្ធសភា និងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការនានាត្រូវមានសមត្ថភាពពេញលេញក្នុងការប្រមូលព័ត៌មាន ស្រាវជ្រាវ និងផ្ដល់យោបល់ជូនគណៈកម្មការក្នុងការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង។ សមាជិកគណៈកម្មការ ព្រមទាំងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការត្រូវរួមចំណែកតាក់តែងសេចក្ដីព្រាងរបាយការណ៍របស់គណៈកម្មការ ស្ដីពីការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ឱ្យបានល្អ និងសុក្រឹត ។ ការចាត់ចែងប្រជុំផ្ទៃក្នុងគណៈកម្មការ ឬអន្តរគណៈ-កម្មការជាមួយតំណាងរាជរដ្ឋាភិបាល "ម្ចាស់សេចក្ដីព្រាងច្បាប់" ឬតំណាងហត្ថលេខីនៃសេចក្ដីស្នើច្បាប់ ត្រូវប្រព្រឹត្តឡើងដោយល្អ និងរលូន ដោយមានឯក

សារគ្រប់សព្វ និងកម្រងនៃសំណួរជាតន្ទឹះ ដែលត្រូវបញ្ជាក់សួរទៅតំណាងរាជរដ្ឋាភិបាល ឬតំណាងហត្ថលេខី ។

-គណៈកម្មការនានា ក្រុម និងសមាជិកព្រឹទ្ធសភា អាចទាញយកផលប្រយោជន៍ និងប្រើប្រាស់សេវាស្រាវជ្រាវឯកទេសរបស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងជាពិសេសពីជួរអ្នកស្រាវជ្រាវ ជាអ្នកឯកទេសជាតិ តំបន់ និងអន្តរជាតិ ។ ចំពោះសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី ត្រូវផលិតរបាយការណ៍តាមដានការពិភាក្សានៅក្នុងសម័យប្រជុំរដ្ឋសភា និងឯកសារស្រាវជ្រាវសភា និងការសិក្សាផលប៉ះពាល់RIA គន្ទឹះ ឬឯកសារជំនួយស្មារតីឱ្យបានទាន់ពេលវេលា និងចែកជូនគ្រប់ក្រុម និងសមាជិកព្រឹទ្ធសភា ដើម្បីធ្វើជាមូលដ្ឋានមួយនៃការសិក្សាពិចារណាប្រកាន់ជំហរ និងផ្តល់យោបល់ ឬអនុសាសន៍ ។

ក្រោយពីបានទទួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ៖

❶ ក្រុមសមាជិកព្រឹទ្ធសភានីមួយៗ ត្រូវមានទម្លាប់រៀបចំប្រជុំពិគ្រោះយោបល់គ្នាជាមុនរៀងៗខ្លួន ដើម្បី ៖

- ប្រកាន់ជំហរឯកភាពគ្នាច្បាស់លាស់របស់ក្រុមលើមូលដ្ឋាននៃទឡ្ហីករណ៍ជាសមូហភាពរួមរឹងមាំរបស់គណបក្សខ្លួន និងក្រុមខ្លួន

- គ្រប់សមាជិករបស់ក្រុម ស្របតាមតួនាទីដែលមានក្នុងយន្តការគ្រប់កម្រិតរបស់ព្រឹទ្ធសភា ត្រូវយកជំហររួម និងទស្សនៈរួមនេះទៅសម្តែងមតិតស៊ូមតិ និងខិតខំការពារតាមកម្រិតនីមួយៗតាំងពីថ្នាក់គណៈកម្មការរហូតដល់សម័យប្រជុំពេញអង្គព្រឹទ្ធសភាដែលជាវេទិកាចុងក្រោយ ។

- ក្រុមនីមួយៗត្រូវចាត់វាគ្មិនពូកែម្នាក់ ឬច្រើននាក់ ដើម្បីត្រៀមសម្តែងយោបល់រួមរបស់ក្រុមខ្លួន និងតស៊ូមតិដោយថ្លៃថ្នូរតាមពេលវេលាកំណត់នៅក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភា ។

❷ របៀបថ្លែងយោបល់ដើម្បីស្នើសុំវិសោធនកម្មសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់របស់ក្រុមសមាជិកព្រឹទ្ធសភានីមួយៗត្រូវឈរលើការប្រើប្រាស់ឧបករណ៍ជានីតិវិធីច្បាស់លាស់ ។

សភានៃប្រទេសនានាតែងតែប្រើរូបភាពជាញត្តិ ដែលមានពាក្យស្នើសុំមួយច្បាប់បញ្ជាក់នាមបុគ្គល ឬក្រុម គោលបំណង មូលហេតុ ពាក្យ ឃ្លា ឬវាក្យខ័ណ្ឌ ជាដើម ដែលស្នើសុំធ្វើវិសោធនកម្ម ព្រមទាំងពាក្យ ឃ្លា ឬវាក្យខ័ណ្ឌដែលដាក់ស្នើជំនួសវិញ ។

ញត្តិនេះត្រូវបានបញ្ជូនជូនប្រធានអង្គប្រជុំ ដែលត្រូវដាក់ស្នើសុំសម័យប្រជុំពេញអង្គពិចារណា ៖

១- តើសម័យប្រជុំពេញអង្គព្រមទទួលញត្តិនេះមកពិចារណាដែរឬទេ?

២- បើសម័យប្រជុំពេញអង្គព្រមទទួលយកញត្តិនេះមកពិចារណា ប្រធានអនុញ្ញាតឱ្យម្ចាស់សំណើឡើងថ្លែងយោបល់ បន្ទាប់មកឱ្យអង្គប្រជុំមានយោបល់ពិភាក្សា និងជាចុងក្រោយស្នើឱ្យសម័យប្រជុំពេញអង្គអនុម័តយល់ព្រម ឬមិនយល់ព្រមតាមសំណើវិសោធនកម្មជាកម្មវត្ថុរបស់ម្ចាស់ញត្តិ ។

ក្នុងករណីមានសំណើចង់បដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្រុមនីមួយៗក៏ត្រូវអនុវត្តនីតិវិធីតាមការលើកឡើងនូវញត្តិតាមទម្រង់ដូចគ្នានេះផងដែរ ។

នេះគឺជាទម្រង់ រូបភាព និងនីតិវិធីសមស្របដែលសភានៃប្រទេសនានាតែងអនុវត្ត ដើម្បីចៀសវាងការលើកយោបល់ពាសវាលពាសកាល ប្រាសចាករបៀបវារៈ និងខ្វះការប្រមូលផ្តុំដែលធ្វើឱ្យខាតពេលវេលា និងគ្មានប្រសិទ្ធភាព។

-កិច្ចសម្របសម្រួលរវាងគណៈកម្មការនានាត្រូវបានកែលម្អ ។ សេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ផ្សេងៗ ជាអាទិ៍ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុត្រូវបានលើកមកពិភាក្សាដោយគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម និងមានការចូលរួមពីគណៈកម្មការផ្សេងៗទៀត ទៅលើផ្នែកដែលស្ថិតនៅក្នុងវង្វង់សមត្ថកិច្ចរបស់គណៈកម្មការទាំងនោះ។ កិច្ចការនេះបានអនុវត្តខ្លះៗរួចមកហើយ ប៉ុន្តែត្រូវរៀបចំឱ្យបានទៅជាប្រព័ន្ធនីតិវិធីមួយ ដែលគ្រប់តួអង្គពាក់ព័ន្ធអាចសម្តែងនូវតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនឱ្យបានល្អបំផុត ។ ជាពិសេស គណៈកម្មការនីមួយៗត្រូវមានឱកាសបានជួបនឹងក្រសួងស្ថាប័នសាមី ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្ត ឬលទ្ធផលកន្លងមក ឈ្វេងយល់ដឹងឱ្យបានពិតប្រាកដអំពីតម្រូវការ និងទិសដៅនៃដំណើរការ និងលទ្ធផលរំពឹងទុកពីការអនុវត្តនៅក្នុងឆ្នាំខាងមុខ ។

-ការបង្កើត អង្គភាពរៀបចំ និងតាមដានថវិកា (PBO: Parliamentary Budget Office) ជាឧបករណ៍ស្រាវជ្រាវ និងជាប្រភពផ្តល់ទិន្នន័យដើម្បីធ្វើជាសេនាធិការជូនគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម គណៈកម្មការនានា និងព្រឹទ្ធសភាទាំងមូលអំពីការរៀបចំ និងការតាមដានការប្រើប្រាស់ថវិកាជាតិប្រចាំឆ្នាំប្រកបដោយគណនេយ្យភាព និងតម្លាភាពពិតប្រាកដ ព្រមទាំងឈានទៅអនុវត្តការងារតាមដានការអនុវត្តថវិការដ្ឋប្រកបដោយប្រសិទ្ធភាព ។ ច្បាប់ថវិកា និងច្បាប់ទូទាត់ថវិកា ជាច្បាប់ពិសេសប្រចាំឆ្នាំដែលសភាតែងអនុម័តឱ្យបានមុនដំណាច់ឆ្នាំ ជារៀងរាល់ឆ្នាំ ។

-ព្រឹទ្ធសភាសហការជាមួយរដ្ឋសភា និងរាជរដ្ឋាភិបាល ដើម្បីរៀបចំឱ្យបានចេញជារូបរាងនូវកម្មវិធី និងប្រតិទិននៃការកសាងច្បាប់ប្រចាំឆ្នាំនីមួយៗ

របស់ជាតិ ។ ព្រឹទ្ធសភា គណៈកម្មការនានា គណៈកម្មការពិសេស គណៈកម្មការចំពោះកិច្ច ក្រុមសមាជិកព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ ក្រុមសមាជិកាព្រឹទ្ធសភា និងក្រុមផ្សេងៗទៀតរបស់ព្រឹទ្ធសភា ត្រូវរៀបចំឱ្យបាននូវកម្មវិធី ប្រតិទិនការងារ និងរបាយការណ៍ (សកម្មភាព និងការអនុវត្តថវិកា) ប្រចាំសប្ដាហ៍ ខែ និងឆ្នាំ ព្រមទាំងផែនការសកម្មភាពប្រចាំនីតិកាលរបស់ខ្លួន ។

-សមាជិកព្រឹទ្ធសភានឹងទទួលបានបទពិសោធន៍នានា ស្ដីពីការចូលរួមពិនិត្យសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ តាមរយៈការពិគ្រោះយោបល់ ការផ្ដល់អនុសាសន៍ និងការកសាងវិធាននីតិវិធីនានា ព្រមទាំងតាមរយៈសិក្ខាសាលា និងវេទិកាផ្សេងៗក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ និងតាមការផ្លាស់ប្ដូរបទពិសោធន៍ជាមួយសមាជិកសភានៃប្រទេសដទៃ ។

-ក្នុងការអភិវឌ្ឍតួនាទីរបស់គណៈកម្មការនានាលើដំណើរការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ជាចាំបាច់ត្រូវមានមធ្យោបាយគ្រប់គ្រាន់ដូចជា ឯកសារ ទិន្នន័យ និងឯកសារយោង ដែលជាផលិតផលបានមកពីការស្រាវជ្រាវ ។

-ការបញ្ជូនព័ត៌មានពីគណៈកម្មការនានាទៅកាន់សមាជិកព្រឹទ្ធសភាដទៃទៀត ត្រូវបានរៀបចំឡើង តាមរយៈរបាយការណ៍ស្ដីពីការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ និងឯកសារយោងដទៃទៀត ដែលត្រូវរៀបចំ និងចែកចាយឱ្យបានគ្រប់សព្វ និងទាន់ពេលវេលា ។

-ព្រឹត្តិបត្ររបស់គណៈកម្មការនានា ព្រឹត្តិបត្រព័ត៌មានប្រចាំថ្ងៃ និងទស្សនាវដ្ដីព្រឹទ្ធសភា ត្រូវបានតាក់តែង និងបោះពុម្ពផ្សាយទៀងទាត់នូវព័ត៌មានសំខាន់ៗ អំពីការពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែល

ជារបៀបវារៈនៃដំណើរការប្រជុំរបស់ព្រឹទ្ធសភា រួមទាំងយកចិត្តទុកដាក់អភិវឌ្ឍន៍គេហទំព័ររបស់គ្រប់យន្តការ ដើម្បីធានាការផ្សព្វផ្សាយ និងឆ្លើយឆ្លងជាមួយសាធារណជនឱ្យបានទាន់ពេលវេលា ។

-សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវបានពិនិត្យចំពោះភាពរលូននៃប្រព័ន្ធច្បាប់ជាតិ តំបន់ និងអន្តរជាតិ ជាពិសេសរដ្ឋធម្មនុញ្ញ ចំណុចរសើបផ្នែកយេនឌ័រ បរិស្ថាន និងការគោរពសិទ្ធិមនុស្ស ព្រមទាំងការគិតគូរយកចិត្តទុកដាក់ដល់ផលប្រយោជន៍ដោយឡែករបស់ភូមិភាគ ថ្នាក់ក្រោមជាតិ និងមជ្ឈដ្ឋាននានាក្នុងសង្គមជាតិ ។ មានកត្តាដែលត្រូវគិតដល់ត្រង់ថា កម្ពុជាជាសមាជិកអាស៊ាន ជាសមាជិកអង្គការសហប្រជាជាតិ និងជាហត្ថលេខីនៃសន្ធិសញ្ញា អនុសញ្ញា ពិធីសារ កតិកាសញ្ញា និងកិច្ចព្រមព្រៀងតំបន់ និងអន្តរជាតិជាច្រើន ហើយមានក្របខ័ណ្ឌគតិយុត្តជាឯកតោភាគីផង ទ្វេភាគីផង និងជាពហុភាគីផង ។

-ព្រឹទ្ធសភាត្រូវកសាងច្បាប់ស្តីពីថវិកាស្វយ័តរបស់សភាកម្ពុជា ដោយសហការជាមួយរដ្ឋសភា ដើម្បីបង្កើនតួនាទីទទួលខុសត្រូវ តម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់ថវិកាតាមកម្មវិធីរបស់អង្គការនីតិបញ្ញត្តិកម្ពុជា ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

-ព្រឹទ្ធសភាចូលរួមក្នុងដំណើរការធានាឱ្យមានការប្រើប្រាស់ខេមរភាសាឱ្យបានត្រឹមត្រូវនៅក្នុងប្រព័ន្ធច្បាប់ជាតិ សមស្របតាមមាត្រា៥ នៃរដ្ឋធម្មនុញ្ញដែលចែងថា ៖ "ភាសា និងអក្សរដែលប្រើជាផ្លូវការ គឺភាសា និងអក្សរខ្មែរ"។ ព្រឹទ្ធសភាគប្បីមានគំនិតផ្តួចផ្តើម ដោយសហការជាមួយរដ្ឋសភា រាជរដ្ឋាភិបាល

និងរាជបណ្ឌិតសភាកម្ពុជា ដើម្បីជំរុញការរៀបចំកម្រងពាក្យច្បាប់ថ្មីៗ កំណត់និយមន័យនៃពាក្យដែលកំពុងប្រើ ន. ស្តង់ដាក្បួនវេយ្យាករណ៍ ដើម្បីធ្វើឱ្យបទប្បញ្ញត្តិទាំងឡាយកាន់តែច្បាស់លាស់ ហើយកាត់បន្ថយឱ្យបានជាអតិបរមានូវភាពមិនច្បាស់លាស់ក្នុងច្បាប់។

-ព្រឹទ្ធសភាត្រូវបង្កើនសមត្ថភាព ដើម្បីទទួលខុសត្រូវឱ្យបានកាន់តែទូលំទូលាយលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ ព្រមទាំងការរៀបចំក្របខ័ណ្ឌការផ្តល់ធនធាន ឬការផ្ទេរសមត្ថកិច្ចដល់ថ្នាក់ក្រោមជាតិឱ្យបានសមស្របទាន់ពេលវេលា និងមានតុល្យភាព។

-នីតិវិធីនៃការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅក្នុងសម័យប្រជុំព្រឹទ្ធសភាត្រូវបានកែលម្អឱ្យកាន់តែប្រសើរឡើង ទាំងខ្លឹមសារ ទាំងពេលវេលាកំណត់ ជាពិសេស គប្បីលើកកម្ពស់សមត្ថភាពរបស់ក្រុមសមាជិកព្រឹទ្ធសភា និងតំណាងក្រុមជាវាគ្មិនឱ្យបានគ្រប់ជ្រុងជ្រោយ ចំបញ្ហា និងគោរពបានពេលវេលាកំណត់។

-សម្រាប់ការពិនិត្យ សិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ គណៈកម្មការត្រូវពិនិត្យជាដំបូងដោយយកចិត្តទុកដាក់អំពីទម្រង់ និងឱកាសគោលការណ៍ ស្មារតីជាចម្បង និងភាពរលូនរបស់ច្បាប់ធ្វើជានីតិវិធីជាមានបឋមមុនចូលទៅពិនិត្យដោយស៊ីជម្រៅលើខ្លឹមសារ ជំពូក និងមាត្រានីមួយៗនៃសេចក្តីព្រាង ច្បាប់ ឬសេចក្តីស្នើច្បាប់។

-មុននឹងពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ព្រឹទ្ធសភាត្រូវពិភាក្សាជាមួយនឹងរាជរដ្ឋាភិបាល (ក្រសួងតាមខ្សែបណ្តោយ) អំពីគោលបំណង លទ្ធផលរំពឹងទុកនៃច្បាប់ តម្លៃ សារសំខាន់ និងផលប៉ះពាល់ទៅលើប្រជាពលរដ្ឋ បរិស្ថាន ឬទៅលើភូមិភាគ ក្រុមប្រឹក្សាឃុំសង្កាត់ ព្រមទាំងធនធានដែលរាជរដ្ឋាភិបាល

ត្រូវមាន ដើម្បីអនុវត្តន៍ច្បាប់ថ្មីប្រកបដោយប្រសិទ្ធភាពពិតប្រាកដ ផ្តល់អនុសាសន៍ទៅលើការផ្សព្វផ្សាយច្បាប់ និងស្មារតីនៃការកសាងអនុក្រឹត្យឱ្យត្រឹមត្រូវ និងទាន់ពេលវេលា ដើម្បីអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ។

-នីតិវិធីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវរួមបញ្ចូលការយកចិត្តទុកដាក់ដល់ការពិគ្រោះយោបល់ ដោយគ្រប់គណៈកម្មការដើរតួនាទីសំខាន់នៅក្នុងដំណើរការនេះ តាមរយៈការរៀបចំកម្មវិធី និងរបៀបវារៈជាខ្លឹមសារនៃការពិគ្រោះយោបល់ ព្រមទាំងមានអ្នកឯកទេសតាមវិស័យមកពិគ្រោះយោបល់ផង ។

-ដំណើរការប្រជុំព្រឹទ្ធសភា ត្រូវបានកត់ត្រាដោយត្រឹមត្រូវនៅក្នុងកំណត់ហេតុ (សង្ខេប និងពិស្តារ) ដែលត្រូវចែកជូនសមាជិកព្រឹទ្ធសភាគ្រប់រូបបានទាន់ពេលវេលា និងត្រូវរក្សាទុកយូរអង្វែងក្នុងបណ្ណាល័យ និងបណ្ណសារដ្ឋានព្រឹទ្ធសភា ។

-គណៈកម្មការនានាបង្កើនសមត្ថភាពក្នុងការពិនិត្យ សិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលមានចរិតប្រញាប់ពិតប្រាកដ ដោយមានក្របខ័ណ្ឌពេលវេលា និងនីតិវិធីប្រមូលផ្តុំ ដើម្បីជានាថិរវេលាកំណត់ ព្រមទាំងនីតិវិធីគន្លឹះដើម្បីពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ ។

-នីតិវិធីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក្នុងសម័យប្រជុំព្រឹទ្ធសភា ត្រូវតែកំណត់ឱ្យបានកាន់តែសុក្រឹត : ការយល់ព្រម មិនយល់ព្រម ឬបដិសេធ ត្រូវមានលក្ខខណ្ឌពិសេសបញ្ជាក់ឱ្យច្បាស់ ដោយមានលទ្ធភាពផ្សេងៗដូចតទៅ ៖

ក- យល់ព្រមទាំងស្រុងដោយឥតកែប្រែ អាចធ្វើឡើងតាមបីរូបភាព ដោយគ្មានយោបល់ ដោយមានយោបល់ (Comment) និង/ឬដោយមានអនុសាសន៍ (Recommendations) អមទៅជាមួយផង ។

ខ- មិនយល់ព្រមស្នើសុំរដ្ឋសភាឱ្យកែសម្រួលខ្លះអាចធ្វើឡើងតាមបីរូបភាព ដោយគ្មានយោបល់, ដោយមានយោបល់ (Comment) និង/ឬដោយមានអនុសាសន៍ (Recommendations) អមទៅជាមួយផង ។

គ- ការបដិសេធជាអសារបង់អាចធ្វើឡើងតាមបីរូបភាព ដោយគ្មានយោបល់, ដោយមានយោបល់ (Comment), និង/ឬដោយមានអនុសាសន៍ (Recommendations) អមទៅជាមួយផង ។

ឃ- ការដែលព្រឹទ្ធសភាពុំបានឱ្យយោបល់សោះក្នុងរយៈពេលមានកំណត់ទុក ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ ដោយអាចយោងដល់លក្ខខណ្ឌពិសេសមួយចំនួន ដូចតទៅ ៖

ឃ.១-សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់មានភាពបន្ទាន់ ឬវិសាលភាពធំធេងពេក (ច្រើនសិបជំពូក រាប់រយមាត្រា) ដែលគណៈកម្មការ ឬព្រឹទ្ធសភា ពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ ។

ឃ.២-សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់បញ្ជូនមកពុំគ្រប់លក្ខណៈសម្បត្តិ (ខ្វះឯកសារយោងដូចជា សេចក្តីថ្លែងហេតុ, អត្ថាធិប្បាយ ឬរំលងមាត្រា) ។

ឃ.៣-ម្ចាស់សេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ពុំបានអញ្ជើញមកការពារចំពោះមុខគណៈកម្មការតាមកាលកំណត់ ។

ឃ.៤-គណៈកម្មាធិការអចិន្ត្រៃយ៍ពុំអាចកោះប្រជុំ (ដោយខ្វះកូរ៉ុម) ដើម្បីរៀបចំរបៀបវារៈសម័យប្រជុំ ។

ឃ.៥-ឬលក្ខខណ្ឌផ្សេងទៀត ។

-ត្រូវខិតខំបង្ហាញឱ្យប្រជាពលរដ្ឋមើលឃើញ និងជឿជាក់ដោយទុកចិត្ត ថា ព្រឹទ្ធសភាជាអ្នកដើរតួរួមចំណែកជាសារវន្តពិតប្រាកដនៅក្នុងដំណើរការតាក់តែង ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដោយហ្មត់ចត់ និងឈរលើផលប្រយោជន៍ជាតិ និងប្រជាជនពិតប្រាកដ ។

-ការបង្វិលទៅបង្វិលមករវាងរដ្ឋសភា និងព្រឹទ្ធសភា ត្រូវជានាអនុវត្តន៍ឱ្យបានតាមស្មារតីនៃមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ និងការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។ តុល្យភាពនៃក្របខ័ណ្ឌពេលវេលារវាងសភាទាំងពីរត្រូវបានកំណត់ច្បាស់លាស់ ។

-គណៈកម្មការនានារបស់ព្រឹទ្ធសភា បង្កើនអន្តរកម្មជាមួយគណៈកម្មការនានារបស់រដ្ឋសភា ដើម្បីធ្វើសកម្មភាពរួមក្នុងវិស័យច្បាប់ និងការចុះបេសកកម្មរួមទៅមូលដ្ឋាន ឬទៅជកពិសោធន៍នៅសភានៃប្រទេសនានាតាមវិស័យពាក់ព័ន្ធ ព្រមទាំងការធ្វើសិក្ខាសាលា សវនាការ ឬការពិគ្រោះយោបល់រួមផង ។

-ព្រឹទ្ធសភាត្រូវពង្រឹងភាពជាដៃគូជាមួយរដ្ឋសភា និងអាជ្ញាធរសវនកម្មជាតិ ដើម្បីអភិវឌ្ឍន៍សមត្ថភាពសវនកម្ម និងសមត្ថភាពពិនិត្យ និងតាមដានការអនុវត្តច្បាប់ហិរញ្ញវត្ថុ និងទូទាត់ថវិកាប្រចាំឆ្នាំរបស់ព្រឹទ្ធសភា ។

-ក្រោមការដឹកនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា និងអគ្គលេខាធិការដ្ឋានត្រូវសហការជាមួយដៃគូនានា ជាពិសេស វិទ្យាស្ថានសភាកម្ពុជា (PIC) ដើម្បីអភិវឌ្ឍន៍សមត្ថភាពជំនាញសម្រាប់បម្រើសេវាខាងនីតិកម្ម និងស្រាវជ្រាវរបស់នាយកដ្ឋានស្រាវជ្រាវច្បាប់ នាយកដ្ឋានស្រាវជ្រាវទូទៅ នាយកដ្ឋានស្រាវជ្រាវកិច្ចការសភា នាយកដ្ឋានតាមដានថវិកា និងសមិទ្ធផល នាយកដ្ឋានភូមិភាគ និងសមូហភាពដែនដី លេខាធិការដ្ឋានអមគណៈកម្មការ និងក្រុមនានា ។

-ព្រឹទ្ធសភាផ្តួចផ្តើមរៀបចំសេចក្តីស្នើច្បាប់សម្រាប់ប្រធានបទពិសេស ដែលព្រឹទ្ធសភាយល់ថាមានសារសំខាន់ជាបន្ទាន់ចំពោះមុខ ឬក៏យូរអង្វែង ។

-ក្រៅពីគណៈកម្មការនានា ដែលត្រូវពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ក្រុមសមាជិកព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ និងក្រុមសមាជិកា ត្រូវរួមចំណែកដោយសកម្ម ដើម្បីសាកសួរតំណាងរាជរដ្ឋាភិបាលដែលអញ្ជើញមកការពារច្បាប់ឱ្យបំភ្លឺ ឬផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់តាមពេលវេលាកំណត់ និង តាមនីតិវិធីជាធរមាន ។

-អនុលោមតាមរដ្ឋធម្មនុញ្ញ សមាជិកព្រឹទ្ធសភាត្រូវមានសមត្ថភាព ដើម្បីផ្តួចផ្តើមគំនិតស្នើច្បាប់ ឬស្នើធ្វើបច្ចុប្បន្នភាពច្បាប់ជាធរមាន ឬស្នើវិសោធនកម្ម ឬស្នើលុបចោលនូវមាត្រាទាំងឡាយដែលត្រូវនិរាករណ៍ ។ ជាពិសេស ព្រឹទ្ធសភាត្រូវយកចិត្តទុកដាក់ធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់លក្ខន្តិកៈសមាជិកព្រឹទ្ធសភាឱ្យសមស្របតាមដំណាក់កាលនីមួយៗ ដោយមានសេចក្តីកំណត់អំពីនីតិវិធី និងឧបករណ៍អនុវត្តគោលការណ៍ គោលនយោបាយ បទដ្ឋានគតិយុត្ត និងផែនការប្រតិបត្តិឱ្យបានច្បាស់លាស់ ។

### ២-យុទ្ធសាស្ត្រអាទិភាពទី២: ការពង្រឹងពង្រីកមុខងារតាមដានការអនុវត្តច្បាប់

-ព្រឹទ្ធសភាត្រូវខិតខំតាមដានមើលការអនុវត្តច្បាប់ រួមទាំងថវិការដ្ឋ ផែនការ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ជាពិសេស យកចិត្តទុកដាក់តាមដានមើលការរៀបចំ និងដាក់អនុវត្តនូវបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងថ្នាក់ក្រោមជាតិ។ គ្រប់កាលៈទេសៈ ព័ត៌មាន និងទិន្នន័យសត្យានុម័ត និងគ្រប់ជ្រុងជ្រោយ គឺជាប្រភពពុំអាចខ្វះបានសម្រាប់ការអនុវត្តមុខងារត្រួតពិនិត្យរបស់ព្រឹទ្ធសភា ។

-ព្រឹទ្ធសភា ត្រូវតែបង្កើនការពិភាក្សាបែបស្ថាបនាជាមួយរាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធដើម្បីឈ្វេងយល់ពីគោលបំណង សំណូមពរ យុទ្ធសាស្ត្រ បរិបទ និងលទ្ធផលអនុវត្តជាក់ស្តែងតាមដំណាក់កាលនីមួយៗរបស់រាជរដ្ឋាភិបាល និងក្រសួងនានា ព្រមទាំងគោលបំណង មូលហេតុ ទឡ្ហីករណ៍ និងបរិបទសមស្របសម្រាប់ការបង្កើតច្បាប់ថ្មី ឬវិសោធនកម្មច្បាប់ចាស់ ឬនិរាករណ៍ច្បាប់ចាស់ ។

-គណៈកម្មការនានា និងក្រុមសមាជិកព្រឹទ្ធសភា ត្រូវមានសមត្ថភាពគ្រប់គ្រាន់ និងជំនួយពីក្រុមអ្នកឯកទេសតាមវិស័យ ជួយគាំទ្រខាងការស្រាវជ្រាវតាមមុខសញ្ញា និងវិស័យជាសមត្ថកិច្ចរបស់ខ្លួន ។

-គណៈកម្មការនានារបស់ព្រឹទ្ធសភា ត្រូវតាមដានមើល និងអនុវត្តការប្រមូលព័ត៌មាន និងវាយតម្លៃជាទៀងទាត់ ហើយធ្វើរបាយការណ៍វាយតម្លៃ និងលើកយោបល់ ឬអនុសាសន៍ជូនព្រឹទ្ធសភាអំពីវិស័យទទួលខុសត្រូវជាសមត្ថកិច្ចរបស់ខ្លួន។ ជាពិសេស គណៈកម្មការនីមួយៗត្រូវមានរបាយការណ៍ចន្លោះសម័យប្រជុំជូន គណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា ដើម្បីព្រឹទ្ធសភាពិចារណាផ្តល់យោបល់ និងលើកអនុសាសន៍តាមវិស័យសមស្របជូនរាជរដ្ឋាភិបាល ឬក្រសួងពាក់ព័ន្ធ ។

-គណៈកម្មការនានា និងក្រុមទាំងឡាយ ត្រូវផ្តួចផ្តើមគំនិតរៀបចំការពិគ្រោះយោបល់ជាសាធារណៈ ឬវេទិកាសាធារណៈតាមការចាំបាច់ជាក់ស្តែងក្នុងកម្រិត ជាតិ ឬថ្នាក់ភូមិភាគ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬឃុំ សង្កាត់ ។

-សកម្មភាពតាមដានការអនុវត្តច្បាប់ និងផ្តល់អនុសាសន៍របស់ព្រឹទ្ធសភាអាចធ្វើទៅបាន ដោយសារការអភិវឌ្ឍសមត្ថភាពជំនាញខាងការស្រាវជ្រាវប្រមូលព័ត៌មាន វិភាគ សំយោគ វាយតម្លៃ និងផ្តល់អនុសាសន៍ ដោយចាំបាច់

ត្រូវបណ្តុះបណ្តាលសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឱ្យមានឯកទេសចាំបាច់គ្រប់គ្រាន់ និងចំសេចក្តីត្រូវការពិតប្រាកដ ។

-ព្រឹទ្ធសភាត្រូវមាននីតិវិធី និងឧបករណ៍អនុវត្តការងារក្នុងកាលៈទេសៈពិសេសរបស់ប្រទេសជាតិដែលអាចបណ្តាលមកពីការឈ្លានពាន ពីបរទេស ការរាតត្បាតនៃជំងឺសាហាវ ឬគ្រោះមហន្តរាយធម្មជាតិឬការគំរាមកំហែងដល់សន្តិសុខ សណ្តាប់ធ្នាប់សុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងជាតិទាំងមូល ។

-វិធាននីតិវិធីរបស់ព្រឹទ្ធសភា ត្រូវមានចែងពីបទប្បញ្ញត្តិ និងផែនការយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទង និងទំនាក់ទំនងសាធារណៈរបស់ស្ថាប័ន ដើម្បីធានាឱ្យមាននូវការប្រាស្រ័យទាក់ទងគ្នាជាមួយរដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ គ្រប់ស្ថាប័នជាតិ និងក្រោមជាតិ វិស័យឯកជន សមាគមអង្គការមិនមែនរដ្ឋាភិបាល ក្រុមប្រឹក្សាឃុំសង្កាត់គ្រប់ភូមិភាគ និងសាធារណជនស្របទៅតាមសេចក្តីត្រូវការចាំបាច់របស់ព្រឹទ្ធសភា ។

-ក្នុងប្រព័ន្ធសភា ព្រឹទ្ធសភាត្រូវមានគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា គណៈកម្មការពិសេស ក្រុមសមាជិកព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ ក្រុមសមាជិកាព្រឹទ្ធសភា ក្រុមទទួលបន្ទុកការងារអន្តរសភា ក្រុមមិត្តភាពជាដើម ដើម្បីបំពេញភារកិច្ចជាក់លាក់ដូចមានចែងក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ សមាជិកព្រឹទ្ធសភាត្រូវទទួលបានព័ត៌មានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា ដោយនិរន្តរភាពអំពីសេចក្តីសម្រេចរបស់ស្ថាប័នផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការតាក់តែងច្បាប់ បទប្បញ្ញត្តិ និងដំណើរការបន្តបន្ទាប់ ព្រមទាំងព័ត៌មានអំពីកិច្ចការផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ ព័ត៌មានទាំងនេះត្រូវធានាទទួលបានសព្វគ្រប់ទាន់ពេលវេលាតាមវិធាននីតិវិធី

ទាំងជាឯកសារជាក្រដាស ទាំងក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងក្នុងគេហទំព័ររបស់ព្រឹទ្ធសភា ។ ឯកសារដែលបានបោះពុម្ពផ្សាយដោយស្ថាប័នសាធារណៈ ត្រូវតែចាត់ចែងជូនសមាជិកព្រឹទ្ធសភាយកទៅប្រើប្រាស់បានតាមការចាំបាច់ ស្របតាមច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ។

-តាមរយៈគណៈកម្មការនានា ព្រឹទ្ធសភាត្រូវតាមដានមើលការរៀបចំលិខិតបទដ្ឋានក្រោមច្បាប់ ដែលតាក់តែងដោយរាជរដ្ឋាភិបាលដើម្បីជានាអនុវត្តនូវច្បាប់ដែលបានចូលជាធរមានរួចហើយ ។ គណៈកម្មការនានាត្រូវបង្កើនការសន្ទនាជាប្រចាំជាមួយក្រសួងពាក់ព័ន្ធតាមវិស័យ ដើម្បីទទួលបានព័ត៌មានថ្មីទាន់ហេតុការណ៍ និងចំតម្រូវការរបស់គណៈកម្មការ ។

-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ត្រូវយកចិត្តទុកដាក់តាមដានការអនុវត្តច្បាប់ថវិការដ្ឋប្រចាំឆ្នាំ និងច្បាប់ទូទាត់ថវិការដ្ឋដែលអង្គនីតិប្បញ្ញត្តិបានអនុម័តជាទៀងទាត់ ។

-សមាជិកព្រឹទ្ធសភាគ្រប់រូប ត្រូវចេះជំនាញរៀបចំកម្រង ឬបញ្ជីសំណួរបទអន្តរាគមន៍ តាមពេលវេលាកំណត់ និងរស់រវើកជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដើម្បីតាមដានមើលការអនុវត្តច្បាប់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ។

-សមាជិកព្រឹទ្ធសភាគ្រប់រូបត្រូវខិតខំអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវសង្កេត តាមដាន ប្រមូលព័ត៌មាន វិភាគ សំយោគ វាយតម្លៃ និងផ្តល់យោបល់ ចេះអង្កេត សាកសួរ និងចុះតាមដានដល់កន្លែង (ក្រសួង និងមូលដ្ឋាន) ជាពិសេសចំពោះ បញ្ហារសើប ឬជាបញ្ហាបច្ចុប្បន្នភាព ដែលមានវិសាលភាពគ្រោះថ្នាក់ និងភាពរសើបខ្ពស់ ។

## ៣-យុទ្ធសាស្ត្រអាទិភាពទី៣ : ការពង្រឹងពង្រីកមុខងារតំណាង

*-រហូតមកទល់ពេលនេះ ការយល់ដឹងជាសាធារណៈអំពីតួនាទីរបស់ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាបានទូលំទូលាយជាបន្តរ ។ ការប្រាស្រ័យឆ្លើយឆ្លងរវាងប្រជាពលរដ្ឋក៏ដូចជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយតំណាងរបស់ខ្លួននៅមានកម្រិតតិចតួចនៅឡើយ ។ ព្រឹទ្ធសភាត្រូវបន្តខិតខំបង្កើតវិធីសាស្ត្រផ្សេងៗ ដូចជាការបោះពុម្ពផ្សាយនូវកូនសៀវភៅព័ត៌មាន ទស្សនាវដ្ដី ការរៀបចំកម្មវិធីវិទ្យុ ទូរទស្សន៍ គេហទំព័រ បណ្ដាញសង្គម និងបង្កើតគោលនយោបាយទំនាក់ទំនងសាធារណៈ និងមជ្ឈមណ្ឌលព័ត៌មានចល័តសម្រាប់ផ្ដល់ព័ត៌មានដល់គ្រប់មជ្ឈដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានកាន់តែទូលំទូលាយរបស់ប្រជាពលរដ្ឋ យុវជន កុមារ គ្រប់ស្ថាប័នរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់អំពីព្រឹទ្ធសភា។ ទន្ទឹមនោះ ត្រូវរៀបចំដំណើរទស្សនកិច្ចសិក្សារបស់សិស្ស និស្សិត និងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់តាមភូមិភាគ សមាគម និងមន្ត្រីរាជការពីក្រសួង ស្ថាប័ននានាមកកាន់ព្រឹទ្ធសភា ដើម្បីបង្កើនការយល់ដឹងអំពីស្ថាប័នព្រឹទ្ធសភា និងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ត្រូវមានកម្មវិធីផ្ដល់ព័ត៌មានចាំបាច់របស់ព្រឹទ្ធសភាដល់តំណាងក្រសួង ស្ថាប័ន និងអង្គការសារព័ត៌មានជាតិ និងសាធារណៈជននៅតាមភូមិភាគនីមួយៗ ។*

*- **ការបង្កើនទំនាក់ទំនង និងបេសកកម្មជាប្រព័ន្ធទៅមូលដ្ឋាន** : ការអនុវត្តទាំងស្រុងនូវតួនាទីជាតំណាងរបស់សមាជិកព្រឹទ្ធសភា ត្រូវមានបណ្ដាញត្រឹមត្រូវសម្រាប់បញ្ជូនព័ត៌មានថ្មីៗពីមូលដ្ឋានទៅកាន់សមាជិកព្រឹទ្ធសភា និងពីសមាជិកព្រឹទ្ធសភាទៅកាន់ម្ចាស់ឆ្នោត ទាក់ទងនឹងបញ្ហាប្រសិទ្ធភាពដំណើរការអនុវត្តនៃគោលនយោបាយ និងច្បាប់ផ្សេងៗរបស់រាជរដ្ឋាភិបាល បំណងប្រាថ្នា និងសំណូមពររបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងការតវ៉ាផ្សេងៗ...។ល។*

ព្រឹទ្ធសភា ត្រូវបន្តរៀបចំដំណើរបេសកកម្មទៅកាន់មូលដ្ឋាន ជាពិសេសនៅកម្រិតគណៈកម្មការនានា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ និងក្រុមសមាជិកាព្រឹទ្ធសភា ។ នាយកដ្ឋានភូមិភាគ និងសមូហភាពដែនដី ការិយាល័យអមក្រុមភូមិភាគ និងអមក្រុមសមាជិកា នាយកដ្ឋានព័ត៌មាន នាយកដ្ឋានព័ត៌មានវិទ្យា បណ្ណាល័យ ត្រូវបង្កើនសមត្ថភាពឯកទេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងផ្តល់សេវាតាមតួនាទីក្នុងការប្រមូលព័ត៌មាន វិភាគ សំយោគ វាយតម្លៃអំពីព័ត៌មានរបស់មូលដ្ឋាននានា ដើម្បីបញ្ជូនទៅសមាជិកព្រឹទ្ធសភា និងគណៈកម្មការនានាឱ្យបានទាន់ពេលវេលា ទាន់ហេតុការណ៍ និងទាន់តម្រូវការ ។

ទន្ទឹមនោះ ត្រូវបង្កើនសមត្ថភាពវិភាគ សំយោគ និងវាយតម្លៃអំពីពាក្យបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ បង្កើតនីតិវិធីសម្រាប់ការគ្រប់គ្រងពាក្យបណ្តឹងតវ៉ា ប្រព័ន្ធឆ្លើយឆ្លងជាមួយសមត្ថកិច្ចក្រសួងស្ថាប័នពាក់ព័ន្ធ និងការឆ្លើយតបដោយឆាប់រហ័សទៅម្ចាស់ពាក្យបណ្តឹងវិញ ។

- **ការពិគ្រោះយោបល់ជាសាធារណៈ និងវេទិកាសាធារណៈ** : ទាំងក្នុងការអនុវត្តមុខងារនីតិកម្ម និងមុខងារតាមដានការអនុវត្តច្បាប់ ផែនការ និងគោលនយោបាយនានា ជាពិសេសនៅថ្នាក់គណៈកម្មការនានា ព្រឹទ្ធសភាត្រូវតែខិតខំស្រាវជ្រាវស្វែងរកការពិត ដើម្បីវាយតម្លៃថាតើបទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ផែនការ ឬគោលនយោបាយទាំងនោះមានលក្ខណៈសមស្រប និងប្រជាពលរដ្ឋអាចទទួលយកបានដែរឬទេ ។ នីតិវិធីលម្អិតក្នុងការពិភាក្សា និងពិគ្រោះយោបល់ក្នុងវេទិការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ឬថ្នាក់មូលដ្ឋាន តាមរយៈវេទិកាសាធារណៈ ដើម្បីផ្តល់យោបល់ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ផែនការ ឬគោលនយោបាយនានា ជាសមត្ថកិច្ចចាត់ចែងរៀបចំរបស់គណៈកម្មការ និងក្រុមភូមិភាគនានា ។ ដើម្បីពង្រឹង

គុណភាពច្បាប់ និងសមត្ថភាពក្នុងការតាមដានការអនុវត្តច្បាប់ ផែនការ និង គោលនយោបាយនានា ព្រឹទ្ធសភាត្រូវរៀបចំការពិគ្រោះយោបល់ ជាសាធារណៈ ឬវេទិកាសាធារណៈ ដោយមានការចូលរួមពីក្រុមប្រឹក្សាឃុំសង្កាត់ ប្រជាពលរដ្ឋ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីបានស្តាប់អំពីយោបល់ និង ទស្សនៈរបស់សាធារណៈមតិ ។

-សមាជិកព្រឹទ្ធសភាម្នាក់ៗដែលជាតំណាងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅតាមភូមិភាគ ត្រូវផ្សារភ្ជាប់ជិតស្និទ្ធជាមួយនឹងមូលដ្ឋាននីមួយៗ តាមរយៈ ការប្រាស្រ័យទាក់ទងដ៏សកម្ម ការចុះដល់មូលដ្ឋាន និងការរៀបចំវេទិកាផ្សេងៗ (វេទិកាសាធារណៈ ឬវេទិកាផ្តល់ព័ត៌មាន) ដោយមានកម្មវិធីទៀងទាត់ ។

-ព្រឹទ្ធសភាបំពេញបាននូវតួនាទីចម្បងជាតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងប្រទេស និងជាកម្លាំងចលករ ដើម្បីជានាជោគជ័យនៃការអនុវត្តគោល នយោបាយវិមជ្ឈការ វិសហមជ្ឈការរបស់រដ្ឋនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និង ការអភិវឌ្ឍឃុំសង្កាត់លើគ្រប់វិស័យ ។

-នៅតាមភូមិភាគនីមួយៗ ត្រូវមានកម្មវិធីប្រចាំឆ្នាំរៀបចំវេទិកាភូមិភាគ ឬរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ វេទិកាក្រុមសមាជិកា ឬវេទិកាអន្តរ ភូមិភាគ ឬអន្តរខេត្ត ក្រុង ស្រុកខណ្ឌ ឃុំ សង្កាត់ ។

-ព្រឹទ្ធសភាត្រូវដាក់អនុវត្តន៍នូវក្រមសីលធម៌សម្រាប់សមាជិកព្រឹទ្ធសភា ដើម្បីបង្កើនជំនឿទុកចិត្តរបស់ម្ចាស់ឆ្នោត និងសាធារណជនទៅលើភាពតំណាង របស់សមាជិកព្រឹទ្ធសភាគ្រប់រូប ហើយសមស្របតាមស្មារតីនៃច្បាប់ស្តីពីការ ប្រឆាំងអំពើពុករលួយដែលធានាដល់តម្លាភាព និងគណនេយ្យភាព នៃជីវិត នយោបាយរបស់សមាជិកព្រឹទ្ធសភា ។ ការប្រកាសទ្រព្យសម្បត្តិត្រូវធ្វើដោយ ស្មោះត្រង់ ត្រឹមត្រូវ និងទៀងទាត់តាមពេលវេលាកំណត់ ។

-តាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា ត្រូវចូលរួមដោយសកម្មក្នុងអង្គសមាជតាមរយៈការកោះប្រជុំពីគណៈកម្មាធិការសមាជ ។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភារកិច្ចផ្តល់សេវាចាំបាច់ជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ដោយបង្កើនកិច្ចសហប្រតិបត្តិការល្អ និងដោយរលូនជាមួយអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

-គណៈកម្មការនានាអាចរៀបចំ និងដឹកនាំធ្វើសវនាការសាធារណៈនៅខាងក្រៅព្រឹទ្ធសភា ឬក្នុងព្រឹទ្ធសភា អំពីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ផែនការ ឬគោលនយោបាយសំខាន់ៗមួយចំនួន ដែលផ្តល់ឱកាសឱ្យសាធាណជន វិស័យឯកជន និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់គំនិត និងបង្ហាញកង្វល់ដោយស្តាបនាបាន ។

-ចូលរួមជំរុញការបោះពុម្ព និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវច្បាប់ដែលអង្គនីតិបញ្ញត្តិបានអនុម័ត និងប្រកាសឱ្យប្រើរួចហើយ ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ជាពិសេស ការធ្វើឧទ្ទេសនាមផ្សព្វផ្សាយច្បាប់សំខាន់ៗជូនសាធារណជនគ្រប់មជ្ឈដ្ឋានឱ្យបានយល់ដឹងអំពីការវិវត្តថ្មីៗនៃប្រព័ន្ធច្បាប់ជាតិ និងកាតព្វកិច្ចថ្មីរបស់ប្រជាពលរដ្ឋ ។

-បង្កើនសកម្មភាពទំនាក់ទំនងរវាងសមាជិកព្រឹទ្ធសភាជាមួយប្រជាពល-រដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់នៅតាមបណ្តាភូមិភាគ ។

-កសាងទំនាក់ទំនងវិជ្ជមាន ប្រកបដោយផ្លែផ្ការវាងសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅតាមរាជធានី ខេត្ត ព្រមទាំងរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អង្គការវិជ្ជាជីវៈ អង្គការអន្តរជាតិ ព្រមទាំងវិស័យឯកជនជាមួយ ព្រឹទ្ធសភា ។

ព្រឹទ្ធសភាត្រូវរួមចំណែកជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីជានាថា ៖

១/-ថវិកាអភិវឌ្ឍថ្នាក់ក្រោមជាតិប្រចាំឆ្នាំត្រូវបានបង្កើន ព្រមទាំងរាល់ការប្រគល់តួនាទី ភារកិច្ចថ្មីបន្ថែមពីរដ្ឋដល់មូលដ្ឋាន ត្រូវអមជាមួយនឹងការបន្ថែមធនធាន និងមធ្យោបាយសមស្របពីរដ្ឋ ដើម្បីមូលដ្ឋានបំពេញភារកិច្ចទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព ។

២/-រាជរដ្ឋាភិបាលយកចិត្តទុកដាក់គិតគូរដល់ជីវភាពទូទៅ និងលក្ខន្តិកៈដោយឡែករបស់មន្ត្រីរាជការបម្រើការនៅថ្នាក់ក្រោមជាតិ ចាប់ពីថ្នាក់ភូមិឡើង ជាពិសេស សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទូទាំងប្រទេស ។

-ព្រឹទ្ធសភាត្រូវមានសមត្ថភាពគ្រប់គ្រាន់ដើម្បីពន្យល់ដល់សាធារណជនអំពីតួនាទី ការទទួលខុសត្រូវ និងសកម្មភាពរបស់ព្រឹទ្ធសភាក្នុងនាមជាចំណែកមួយនៃអង្គនីតិប្បញ្ញត្តិកម្ពុជា ដើម្បីបម្រើដល់បុព្វហេតុនីតិរដ្ឋ និងអភិបាលកិច្ចល្អ ។

-សហការជាមួយរដ្ឋសភា និងក្រសួងអប់រំ យុវជន និងកីឡា រៀបចំ និងបង្កើតមុខវិជ្ជាអំពីលទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត តួនាទីសភា និងភាពជាតំណាងតាមបែបប្រជាធិបតេយ្យសម្រាប់ជាចំណេះដឹងទូទៅដល់សិស្សានុសិស្សចាប់ពីកម្រិតមធ្យមសិក្សាឡើងទៅ ព្រមទាំងនិស្សិត និងសាធារណជននានា ។

-សិក្សាអំពីការរៀបចំវេទិកាព្រឹទ្ធសភាយុវជន ឬព្រឹទ្ធសភាកុមារ ឬទិវាបើកចំហរក្នុងមួយឆ្នាំម្តង ជាគុណប្រយោជន៍ដល់ការផ្សព្វផ្សាយជាសាធារណៈអំពីព្រឹទ្ធសភា ។

-រៀបចំសិក្ខាសាលាអំពីទស្សនៈនៃវប្បធម៌សន្ទនា និងសិល្បៈនៃការសម្រុះសម្រួលគ្នា និងសម្របសម្រួលគ្នា ជាគុណប្រយោជន៍ដល់ការកសាងបរិយាកាស និងបរិស្ថានអនុគ្រោះក្នុងដំណើរការនយោបាយ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សប្រកបដោយភាពវិជ្ជមាន ដោយមានការយោគយល់ និងសហការគ្នាល្អប្រសើរ ក្នុងស្មារតីបង្រួបបង្រួមជាតិក្នុងចំណោមតួអង្គនយោបាយក្នុងព្រឹទ្ធសភា ។

-ផ្សព្វផ្សាយជាសាធារណៈឱ្យបានទាន់ពេលវេលា ដោយទៀងទាត់ អំពីកិច្ចប្រជុំគណៈកម្មការនានា គណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំព្រឹទ្ធសភា (សាមញ្ញ វិសាមញ្ញ) វេទិកា សវនាការសាធារណៈ ឬសិក្ខាសាលាផ្សេងៗ ។

-រៀបចំវេទិការួមរវាងព្រឹទ្ធសភា និងសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន យ៉ាងហោចមួយឆ្នាំម្តង ដើម្បីបង្កើនទំនាក់ទំនងការងារ និងកិច្ចសហប្រតិបត្តិការគ្នាទៅវិញទៅមក ជាពិសេសចែករំលែកព័ត៌មាន និងបទពិសោធន៍ ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាប្រឈមផ្សេងៗនៅថ្នាក់ក្រោមជាតិ ។

-ព្រឹទ្ធសភា ត្រូវរួមចំណែកជំរុញការអភិវឌ្ឍមូលដ្ឋាន ជាពិសេស ការអនុវត្តគោលនយោបាយ "ភូមិមួយ ផលិតផលមួយ" និងគោលនយោបាយ "ភូមិឃុំមានសុវត្ថិភាព" ក្នុងក្របខ័ណ្ឌទូទាំងប្រទេស។ ក្នុងន័យនេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ ក៏ដូចជាក្រុមសមាជិកា អាចចូលរួមអនុវត្តន៍គម្រោងតូចៗតាមមូលដ្ឋាន ដើម្បីកសាងស្នាដៃតាមនីតិកាលនីមួយៗរបស់ព្រឹទ្ធសភា ។ ព្រឹទ្ធសភា និងគណៈកម្មការនីមួយៗ មានថវិកាមួយចំនួនដើម្បីធ្វើការងារសង្គមកិច្ច និងមនុស្សធម៌ ជាគុណប្រយោជន៍ដល់មូលដ្ឋាន ប្រជាពលរដ្ឋ និងម្ចាស់ឆ្នោត ។

-ព្រឹទ្ធសភា ត្រូវខិតខំរៀបចំមួយឆ្នាំម្តងក្នុងបរិវេណព្រឹទ្ធសភានូវពិព័រណ៍សមិទ្ធផលជាស្នាដៃរបស់ថ្នាក់ក្រោមជាតិ ដើម្បីលើកទឹកចិត្តដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាននៅថ្នាក់ឃុំ សង្កាត់ទូទាំង៨ភូមិភាគ។

-ព្រឹទ្ធសភា អាចចាត់ចែងឱ្យមានអគារលក់ផលិតផលសិប្បកម្ម ឬវត្ថុអនុស្សាវរីយ៍ជាផលិតផលរបស់មូលដ្ឋានក្នុងបរិវេណព្រឹទ្ធសភា ដើម្បីជាភស្តុតាងផ្សារភ្ជាប់រវាងព្រឹទ្ធសភា និងសមូហភាពដែនដីទូទាំងប្រទេស ។ ព្រឹទ្ធសភាគួរប្រើប្រាស់ជាផ្លូវការនូវវត្ថុអនុស្សាវរីយ៍ជាផលិតផលរបស់មូលដ្ឋាន ។

- ព្រឹទ្ធសភាបន្តអនុវត្តកម្មវិធីហាត់ការដោយស្ម័គ្រចិត្តរបស់និស្សិតខ្មែរ និងបរទេស ដើម្បីជាធនធានបម្រុងរបស់ស្ថាប័នផង និងជាសកម្មជននៃការផ្សព្វផ្សាយអំពីព្រឹទ្ធសភាជូនដល់សាធារណជនទូទៅក្នុង និងក្រៅប្រទេស និងជាពិសេសដល់ជួរយុវជន ។

- ការបំពាក់បន្ថែមនូវសមត្ថភាព ធនធាន និងមធ្យោបាយ ដើម្បីសមាជិកព្រឹទ្ធសភាអាចអនុវត្តន៍បាននូវភាពជាតំណាងភូមិភាគប្រកបដោយប្រសិទ្ធភាពតាមរយៈការរៀបចំ និងដាក់អនុវត្តន៍ផែនការ កម្មវិធី សកម្មភាព និងថវិកាតាមកម្មវិធីប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងប្រចាំនីតិកាល ។

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ និងក្រុមសមាជិកាព្រឹទ្ធសភាត្រូវមានរបាយការណ៍ អំពីបញ្ហាកើតមាននៅក្នុងភូមិសាស្ត្រ វឌ្ឍនភាពនៃវិស័យយេនឌ័រ លទ្ធផលនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយ និរន្តរភាពរបស់កម្ពុជា ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យពិចារណា និងជូនអង្គព្រឹទ្ធសភាជ្រាប ហើយក្នុងករណីចាំបាច់លើកអនុសាសន៍ដាក់ស្តែងជូនរាជរដ្ឋាភិបាល ។

-ព្រឹទ្ធសភាត្រូវបង្កើនភាពជាដៃគូជាមួយរាជរដ្ឋាភិបាល ដើម្បីជានាថារដ្ឋមានភាពរឹងមាំ ខាងវិស័យសេដ្ឋកិច្ច សង្គម មានធនធានបម្រុងសម្រាប់ដោះស្រាយបញ្ហាពេល ជួបវិបត្តិ ឬហានិភ័យ ហើយស្ថេរភាព សន្តិសុខ និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរឹងមាំគ្រប់កាលៈទេសៈត្រូវរក្សា បានជាមូលដ្ឋាន ។

**៤-យុទ្ធសាស្ត្រអាទិភាពទី៤ : ការពង្រឹងពង្រីកមុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ**

*-មុខងារនេះសំដៅអភិវឌ្ឍទំនាក់ទំនងអន្តរជាតិប្រកបដោយកិត្យានុភាពនិងផ្លែផ្ការបស់ព្រឹទ្ធសភា ។*

-ព្រឹទ្ធសភា ត្រូវរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ផលប្រយោជន៍និងកិត្យានុភាពជាតិនៅក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ដោយមានទំនាក់ទំនងទ្វេភាគីល្អជាមួយសភានៃប្រទេសជាមិត្ត ព្រមទាំងទំនាក់ទំនងពហុភាគីល្អក្នុងក្របខ័ណ្ឌសហភាពអន្តរសភា (IPU) សមាគមអន្តរសភាអាស៊ាន (AIPA) សមាគមសភានៃប្រទេសប្រើភាសាបារាំង (APF) និងអង្គការផ្សេងៗទៀតដូចជា APPF, APA, CLV, ។ល។

-បង្កើនសមត្ថភាពសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើជាមធ្យោបាយនៃការប្រាស្រ័យទាក់ទង និងការប្រជុំអន្តរសភាប្រកបដោយប្រសិទ្ធភាព ។

-តាមរយៈកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃទាំងនេះ ព្រឹទ្ធសភាត្រូវខិតខំផ្លាស់ប្តូរបទពិសោធន៍អំពីកិច្ចការសភា និងចេះទាក់ទាញការគាំទ្រ និងជំនួយដើម្បីអភិវឌ្ឍន៍ស្ថាប័នឱ្យបានឆាប់រហ័ស តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់សភាសម្រាប់ការបណ្តុះបណ្តាល និងផ្លាស់ប្តូរបទពិសោធន៍ ព្រមទាំងការផ្តល់ជំនួយជាសម្ភារ បរិក្ខារ និងទីកន្លែងធ្វើការ ។

-ព្រឹទ្ធសភា ត្រូវមានទំនាក់ទំនងប្រកបដោយផ្លែផ្កាជាមួយស្ថានឯកអគ្គរាជទូត-រដ្ឋទូតនៃប្រទេសជាមិត្ត អង្គការ.ានុរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគមក្នុង និងក្រៅប្រទេស ។ ជាពិសេស ត្រូវយកចិត្តទុកដាក់បំពេញកាតព្វកិច្ចជាមួយដៃគូទាំងឡាយដែលកំពុងជួយ ឬនឹងចូលមកជួយសហប្រតិបត្តិការពហុរូបភាព និងពហុវិស័យឱ្យបានល្អប្រកបដោយផ្លែផ្កា និងមានផលប្រយោជន៍ពិតប្រាកដ ។

ជាពិសេស ត្រូវចាប់អារម្មណ៍ និងយល់ថា ចាប់ពីសតវត្សទី២០មកមានការផ្លាស់ប្តូរ២ដ៏សំខាន់ និងខុសគ្នា ៖

❶ នៅក្នុងសតវត្សនេះមានការកកើតនូវសហប្រតិបត្តិការអន្តរជាតិ ឬពហុភាគី ដោយមានការបង្កើតនូវអង្គការអន្តរជាតិជាច្រើន ។ វិស័យនៃសមត្ថកិច្ចរបស់អង្គការទាំងនេះប៉ះពាល់ទៅស្ទើរតែគ្រប់សកម្មភាពរបស់មនុស្ស សិទ្ធិមនុស្ស និងសិទ្ធិសង្គម នយោបាយ ការងារ និងផ្សេងៗទៀត ។ ស្ថាប័នទាំងនោះគឺជាអាទិភាពនៃការងារអន្តរជាតិរបស់រដ្ឋជាភាគី ដែលតំណាងរបស់រដ្ឋាភិបាលទាំងឡាយធ្វើការសម្រេចចិត្ត និងចុះកិច្ចព្រមព្រៀងជាមួយគ្នាតាមរយៈសន្និសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងនានា ។

សភាត្រូវផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀង ឬឯកសារដែលបានបញ្ចប់រួចហើយ និងអនុម័ត (ឬធ្វើវិសោធនកម្ម) នូវច្បាប់ចាំបាច់នានា ដើម្បីដាក់អនុវត្តជាក់ស្តែងនូវការព្រមព្រៀងទាំងនោះ ។

❷ នៅពាក់កណ្តាលសតវត្សទី២០ មានកកើតនូវដំណើរការសមាហរណកម្មតំបន់ ដែលឆ្លើយតបទៅនឹងមូលហេតុជាច្រើនពីសំណាក់ប្រទេសពាក់

ព័ន្ធ ដែលមានបំណងប្រាថ្នាឆ្ពោះទៅកាន់ការឯកភាពគ្នា ដើម្បីជំនះលើការបែកបាក់គ្នាក្នុងប្រវត្តិសាស្ត្រ និងជានាស្ដេរភាព និងសន្តិភាពតំបន់ ដោយឈរលើជំនឿថា «ការចូលរួមគ្នាគឺជាកម្លាំង»។ ក្រៅពីនេះនៅមានចលនារួមគ្នាកសាងសហគមន៍នៃជោគវាសនារួម ដោយធ្វើសេចក្ដីសម្រេចសំខាន់ៗ ដើម្បីសហគមន៍នោះកាន់តែរលូន និងល្អប្រសើរឡើង ។ ប្រទេសនានាបានសម្រេចធ្វើសមាហរណកម្មជាលំដាប់នូវទីផ្សារសេដ្ឋកិច្ច និងអង្គជាតុ ឬវិស័យផ្សេងទៀតរបស់រដ្ឋរៀងៗខ្លួន ដោយគិតគូរអំពីគោលការណ៍បំពេញបន្ថែម (Principe de subsidiarité) ទៅវិញទៅមក ។

យើងកំពុងរស់នៅក្នុងពិភពលោកមួយដែលកាន់តែពឹងពាក់គ្នាទៅវិញទៅមក ព្រោះវាពាក់ព័ន្ធនឹងបរិស្ថាន សន្តិសុខរូបវ័ន្ត និងសន្តិសុខខាងការផ្លាស់ប្ដូរព័ត៌មាន សុខភាពសាធារណៈ បញ្ហាអន្តោប្រវេសន៍ ឧក្រិដ្ឋកម្ម ការគេចពន្ធ..។ នេះជាបាតុភូតដែលបង្កើនល្បឿននា២០ឆ្នាំចុងក្រោយនេះ ដែលធ្វើឱ្យមានការពឹងពាក់គ្នារវាងប្រទេសនានាកាន់តែខ្លាំងក្លាឡើង ។

នាពេលបច្ចុប្បន្ននេះ ខ្សែបន្ទាត់ដែលបែងចែករវាងនយោបាយក្នុងប្រទេសជាមួយនយោបាយក្រៅប្រទេស ឬអន្តរជាតិកាន់តែលែងច្បាស់លាស់។ ហេតុនេះសភាត្រូវរកមធ្យោបាយដើម្បីដើរហួស ឬជំនះផ្លាស់ប្ដូរនូវទម្លាប់ជាប្រពៃណី ដែលអង្គនីតិប្រតិបត្តិទទួលកាន់កាប់តែឯងនូវនយោបាយអន្តរជាតិ ។ រដ្ឋាភិបាលត្រូវដាក់នយោបាយអន្តរជាតិមកឱ្យសភាតាមដានត្រួតពិនិត្យមើល ដូចនយោបាយខាងក្នុងប្រទេសដែរ ។

វិសាលភាពរបស់សភានៅក្នុងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើឱ្យបានជាក់ស្ដែងដោយសភាខ្លួនឯង តាមរបៀប៤យ៉ាងដែលផ្សារភ្ជាប់គ្នាដូចតទៅ៖

-បង្កើនឥទ្ធិពលទៅលើនយោបាយការបរទេសរបស់ប្រទេសរៀងៗខ្លួន លើបញ្ហាទាំងឡាយដែលត្រូវដោះស្រា[illegible]នៅអង្គការសហប្រជាជាតិ និងវេទិកាចរចាអន្តរជាតិផ្សេងទៀត ។

-ទទួលបានព័ត៌មានអំពីកិច្ចដំណើរការប្រជុំ និងលទ្ធផលនៃការចរចាទាំងឡាយដែលរដ្ឋាភិបាលបានធ្វើ ។

-ផ្តល់សច្ចាប័ន កាលណារដ្ឋធម្មនុញ្ញអនុញ្ញាតទៅលើអត្ថបទសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងដែលចុះហត្ថលេខាដោយរាជរដ្ឋាភិបាល ។

-រួមវិភាគទានយ៉ាងសកម្មដល់ការដាក់អនុវត្តន៍នូវលទ្ធផលនៃការចរចា និងកិច្ចព្រមព្រៀងទាំងឡាយ ។

ដើម្បីសភាមួយអាចដើរតួនាទីមានប្រសិទ្ធភាពលើកិច្ចការអន្តរជាតិសភានោះត្រូវ៖

-មានបទដ្ឋានគតិយុត្តច្បាស់លាស់ ដែលជាគ្រឹះសម្រាប់ការចូលរួមរបស់សភា ។

-ទទួលបានព័ត៌មានអំពីគោលនយោបាយប្រកាន់យកដោយរាជរដ្ឋាភិបាល និងជំហរជុំវិញការចរចាជាមុន ហើយត្រូវបានពិគ្រោះយោបល់ដោយមានព័ត៌មានច្បាស់លាស់ស្តីពីខ្លឹមសារ និងបរិបទនៃគោលនយោបាយដែលគ្រោងប្រកាន់យក ។

-មានការចាត់តាំង និងធនធានគ្រប់គ្រាន់សម្រាប់សិក្សាបញ្ហាទាំងនេះជាពិសេស នៅក្នុងជួរសមាជិកសភាត្រូវមានអ្នកឯកទេស ដើម្បីចូលរួមប្រជុំការងារចាំបាច់របស់គណៈកម្មការឯកទេស ។

-មានលទ្ធភាពចោទសួរសំណួរដល់មន្ត្រី និងអ្នកចរចាពាក់ព័ន្ធ ហើយអាចសម្តែងយោបល់នយោបាយជូនរាជរដ្ឋាភិបាល ទោះបីយោបល់នោះតាមផ្លូវច្បាប់ ពុំមែនជាការចាប់បង្ខំក្តី ។

-ត្រូវរួមបញ្ចូលដោយពេញសិទ្ធិក្នុងគណៈប្រតិភូរដ្ឋាភិបាលទៅប្រជុំនៅឯវេទិកាអន្តរជាតិ ។

## សិទ្ធិមនុស្ស

សភា និងសមាជិកសភាមានតួនាទីគន្លឹះនៅក្នុងការលើកតម្កើង និងកិច្ចការពារសិទ្ធិមនុស្ស ។ សកម្មភាពរបស់សភាទាំងមូលជាអាទិ៍ ធ្វើច្បាប់ អនុម័តថវិកា និងតាមដានត្រួតពិនិត្យរដ្ឋាភិបាល ដែលអនុវត្តការកិច្ចពាក់ព័ន្ធដល់សិទ្ធិនយោបាយ ស៊ីវិល សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ បានន័យថា ចំណាត់ការរបស់រាជរដ្ឋាភិបាល តែងមានផលប៉ះពាល់ដល់ការប្រតិបត្តិសិទ្ធិមនុស្ស ។ ដូច្នេះសភាដើរតួជាឆ្មាំការពារសិទ្ធិមនុស្ស ។

ដើម្បីចូលជាធរមាននូវសន្ធិសញ្ញាអន្តរជាតិ រួមទាំងសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ចាំបាច់មិនអាចខ្វះបាននូវការយល់ព្រមផ្តល់សច្ចាប័នពីសភា ។

## សមភាពរវាងភេទ

សន្ធិសញ្ញាជាច្រើនតម្រូវឱ្យរដ្ឋឱ្យដាក់ជូននូវរបាយការណ៍តាមពេលកំណត់ទៀងទាត់ ស្តីអំពីស្ថានភាពនៃដំណើរទៅមុខក្នុងការអនុវត្តនូវសន្ធិសញ្ញាទាំងនេះនៅក្នុងកម្រិតជាតិ ។ ជាឧទាហរណ៍ ករណីអនុសញ្ញាស្តីពីការលុបបំបាត់នូវគ្រប់រូបភាពនៃការរើសអើងចំពោះនារី និងពិធីសារ (តាមការស្ម័គ្រចិត្ត) ។

តាមគំរូដែលបានធ្វើចំពោះសិទ្ធិមនុស្ស សភាកាន់តែច្រើនបានបង្កើតគណៈកម្មការពិសេស ឬស្ថាប័នដទៃទៀតដែលទទួលបន្ទុកអំពីបញ្ហាសមភាពរវាងភេទ និង/ឬប្រគល់ឱ្យគណៈកម្មការសភាដែលមានស្រាប់នូវអណត្តិអំពីបញ្ហានេះ ។

## ការអភិបាល

បញ្ហានៃការចូលរួមរបស់សភាកាន់តែមានសារសំខាន់ នៅក្នុងការអនុ-វត្តនូវគោលដៅអភិវឌ្ឍន៍ដោយនិរន្តរភាព ។

មានវិធីសាស្ត្រ២របៀប នៃការចូលរួមរបស់សភានៅក្នុងដំណើរការ SDG ដែលមានប្រយោជន៍សម្រាប់ការអនុវត្ត៖

-ការចូលរួមរបស់សមាជិកសភាក្នុងការរៀបចំគោលនយោបាយជាតិ តាមរយៈកិច្ចការដែលបានសម្រេចនៅក្នុងគណៈកម្មការពិសេសរបស់សភា និងសកម្មភាពដែលបានធ្វើក្នុងគណៈកម្មការការងារតាមវិស័យ ។

-ការត្រួតពិនិត្យផ្ទាល់ដល់កន្លែង អំពីការអនុវត្តគោលនយោបាយសំខាន់ៗ ពុំត្រឹមតែដើម្បីផ្ទៀងផ្ទាត់តាមទិដ្ឋភាពគណនេយ្យភាពប៉ុណ្ណោះទេ តែថែមទាំងដើម្បី កំណត់ថាតើគោលនយោបាយនេះអាចកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាពដែរឬទេ ?

## ពាណិជ្ជកម្ម

ផលប៉ះពាល់ខាងច្បាប់ទម្លាប់ (Effects régulateurs)៖ ជាទូទៅសភានានា ពុំមានជម្រើសណាក្រៅពីទទួលយកនូវច្បាប់ទាំងឡាយ ដែលខាងរាជរដ្ឋាភិបាល បានចុះហត្ថលេខាក្នុងក្របខ័ណ្ឌតំបន់ ឬអន្តរជាតិរួចហើយ និងបញ្ជូនមកសភា ដោយពុំអាចធានាច្បាស់បានថា ច្បាប់ទាំងនោះសមស្របទៅនឹងគោលដៅជាតិ និងបំណងប្រាថ្នារបស់ប្រជាជនឡើយ ។

នេះគឺជាវិស័យមួយ ដែលការត្រួតពិនិត្យរបស់សភាទៅលើដំណើរការចរចាដែលមានសារសំខាន់ជាគន្លឹះ ។ សភាជាច្រើនបានប្រកាន់យកវិធានការដើម្បីទទួលបានព័ត៌មានអំពីការរីកចម្រើននៃការចរចា និងខិតខំណែនាំរាជរដ្ឋាភិបាលឱ្យប្រកាន់យកជាបន្តបន្ទាប់នូវគោលនយោបាយសមស្រប ។

## ការចូលរួមរបស់សភានៅក្នុងដំណើរការសមាហរណកម្មតំបន់

តំបន់ជាច្រើននៅលើពិភពលោកកំពុងធ្វើដំណើរទៅតាមទិសសមាហរណកម្ម។ បាតុភូតនេះមានប្រភពដើមនៅអឺរ៉ុប ពង្រីកទៅទ្វីបអាហ្វ្រិក អាមេរិកឡាទីន នៅអាស៊ី និងនៅក្នុងពិភពអារ៉ាប់ ។ ទោះបីប្រទេសទាំងនេះស្ថិតនៅក្នុងដំណាក់កាលខុសគ្នាក្តី តែពួកគេមានចំណុចរួមជាច្រើន។ ប៉ុន្តែសមាហរណកម្មតំបន់នេះ ក៏តែងតែនាំមកនូវការប្រឈមជាច្រើនដល់សភាជាតិនានា ជាពិសេស វិស័យនីតិកម្ម នយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ។

## សហប្រតិបត្តិការសភា

របៀបនៃកិច្ចសហប្រតិបត្តិការសភាទាំងកម្រិតពិភពលោក និងកម្រិតតំបន់ មានរូបភាពជាច្រើន ៖ ការទូតសភា(Diplomatic Parlementaire) សហប្រតិបត្តិការអន្តរសភា(Coopération Interparlementaire) និងសហប្រតិបត្តិការបច្ចេកទេស(Coopération Technique) ។

## ការទូតសភា

ការទូត គឺជាបេសកកម្មរបស់អង្គនីតិប្រតិបត្តិ ដែលត្រូវការពារភាពតំណាងនៅឯបរទេសនូវទស្សនៈរបស់រដ្ឋខ្លួន ។ សមាជិកសភាមិនថាបុរសឬនារី ជាតួអង្គអ្នកនយោបាយដែលមានទស្សនៈផ្ទាល់ខ្លួន ដែលពុំចាំបាច់បង្ខិឱ្យដូចគ្នាទៅនឹងជំហរផ្លូវការរបស់ប្រទេសខ្លួនឡើយ ។ ប្រការនេះបាននាំឱ្យពួកគេមានក្របខ័ណ្ឌយុទ្ធវិធីងាយស្រួលបត់បែន ដែលអ្នកការទូតគ្មាន ។ ភាពទន់ភ្លន់នេះបានអនុញ្ញាតឱ្យសមាជិកសភាពិភាក្សាដោយសេរីជាមួយសហសេវិកនៃប្រទេសផ្សេងទៀត និងលើកឡើងនូវសំណើថ្មីៗ ចំពោះបញ្ហាខ្វះដែលទាល់ច្រក ហើយហាក់ដូចជាពុំអាចដោះស្រាយបានរហូតមកដល់ពេលនោះ។

ការទូតសភាពុំត្រឹមតែជាទំនាក់ទំនងរវាងសមាជិកសភាប៉ុណ្ណោះទេ ។ សមាជិកនៃសភាមួយអាចធ្វើដំណើរទៅកាន់ប្រទេសមួយទៀត ដើម្បីជួបសន្ទនាជាមួយអ្នកដឹកនាំនៃស្ថាប័នផ្សេងៗដើម្បីរិះរកដោះស្រាយបញ្ហា ឬដើម្បីបញ្ចប់ជម្លោះ ។

**សហប្រតិបត្តិការសភា**

ក្នុងទសវត្សចុងក្រោយ មានការបង្កើនការផ្លាស់ប្តូររវាងសភាជាច្រើនរូបភាព ។

សភាទាំងអស់បានចាប់ផ្តើមជារូបភាពសហប្រតិបត្តិការទ្វេភាគី ដូចជាបង្កើតក្រុមមិត្តភាពទ្វេភាគី ដើម្បីជំរុញសហប្រតិបត្តិការរវាងសភា និងប្រទេសសាមី ។

ក្រៅពីនោះ មានបណ្តាញមិនផ្លូវការរបស់សមាជិកសភា ដែលជួបជុំគ្នាដើម្បីពិចារណាដោះស្រាយអំពីបញ្ហាជាក់ស្តែងផ្សេងៗ ដូចជាបញ្ហាពាក់ព័ន្ធដល់ការអភិវឌ្ឍ ឬដល់ប្រជាសាស្ត្រ ការបន្ថយសព្វាវុធ ឬអាវុធធុនខ្លី...។ល។

បណ្តាញរបស់សមាជិកសភាដើម្បីសកម្មភាពទាំងស្រុង (PGA: Parliamentarians for Global Action) មានកម្មវត្ថុជាច្រើន ជាពិសេស ទទួលបានជោគជ័យដើម្បីប្រមូលផ្តុំសាធារណជនឱ្យគាំទ្រដល់ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ក្រៅពីនោះ មានរចនាសម្ព័ន្ធសភាដែលមានលក្ខណៈផ្លូវការដូចជាសមាគមសភា Commonwealth និងសមាគមសភានៃប្រទេសប្រើភាសាបារាំង (APF)...។ល។

គេឃើញមានផងដែរនូវអង្គការសភាតំបន់ និងអនុតំបន់ (Assemblées Parlementaires Régionales et sous-Régionales) ។ ជានិន្នាការបច្ចុប្បន្ន សភានានាបានឧទ្ទិសកាន់តែច្រើននូវពេលវេលា និងធនធានសម្រាប់សហប្រតិបត្តិការសភានៅក្នុងក្របខ័ណ្ឌតំបន់ ។

អង្គការសភាតំបន់មានការខិតខំជារួម ដើម្បីជំរុញសមាហរណកម្ម តំបន់ និងការសហការគ្នាកាន់តែល្អប្រសើរឡើងរវាងប្រទេសជាសមាជិក ។

**ការជួយខាងបច្ចេកទេស**

ពាក្យថា ការជួយខាងបច្ចេកទេស (Assistance Technique) និយាយដល់វិធានការប្រកាន់យកដោយស្ថាប័ន ឬដោយបុគ្គលនានា ដើម្បីជួយពង្រឹងដល់សមត្ថភាពរបស់សភាណាមួយ ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសប្រជាធិបតេយ្យថ្មី ដើម្បីឱ្យសភាទាំងនោះបំពេញបាននូវមុខងាររបស់ខ្លួនៗ ការជួយខាងបច្ចេកទេសកើតចេញពីទស្សនៈថា សភាមួយដែលនៅក្មេងខ្ចីនៅឡើយ តែងខ្វះខាតនូវធនធានមនុស្ស និងសម្ភារដែលខ្លួនត្រូវការ ដើម្បីបំពេញដោយមានប្រសិទ្ធភាពនូវអាណត្តិដែលប្រគល់ដោយរដ្ឋធម្មនុញ្ញ ។ គេអាចកំណត់អំពីជំនួយខាងបច្ចេកទេស ថាជាសំណុំនៃមធ្យោបាយហិរញ្ញវត្ថុ សម្ភារ និងឯកទេស (Expertise) ដែលប្រទេសប្រជាធិបតេយ្យដ៏រឹងមាំ និងប្រទេសអភិវឌ្ឍន៍នៅខាងជើងផ្តល់ដល់សភានៃប្រទេសប្រជាធិបតេយ្យទើបកកើត និងប្រទេសកំពុងអភិវឌ្ឍន៍នៅខាងត្បូង ។

ការជួយខាងបច្ចេកទេសអាចមានរូបភាពផ្សេងៗដូចតទៅ៖ ការអភិវឌ្ឍរចនាសម្ព័ន្ធ ការអភិវឌ្ឍស្ថាប័ន តាមរយៈការបញ្ចូលនីតិវិធីថ្មីដែលបានកែលំអ ឬការធ្វើទំនើបកម្មនូវដំណើរការសភា ការណែនាំតាមរយៈការផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មានរវាងសមាជិកសភានៃប្រទេសផ្សេងៗ ការពង្រឹងសមត្ថភាព និងវិសិដ្ឋកម្មវិជ្ជាជីវៈ (ការបណ្តុះបណ្តាលមន្ត្រី និងសមាជិកសភា) និងការអភិវឌ្ឍនូវសមត្ថកិច្ចខាងច្បាប់ (នៅក្នុងក្របខ័ណ្ឌដែលសភាបានទទួលនូវការជួយឧបត្ថម្ភក្នុងពេលរៀបចំតាក់តែងច្បាប់ថ្មី ឬវិសោធនកម្មអត្ថបទច្បាប់ចាស់ពីមុន) ។

ជាធម្មតា ការជួយខាងបច្ចេកទេសអាចគ្របដណ្តប់ទៅលើវិស័យផ្សេងៗដូចជា៖ បទបញ្ជាផ្ទៃក្នុងរបស់សភា និងបទដ្ឋាននៃនីតិវិធីផ្សេងៗទៀត ប្រព័ន្ធគណៈកម្មការ នីតិកម្ម មុខងារតំណាងរបស់សភា មុខងារត្រួតពិនិត្យ រដ្ឋបាល បណ្ណាល័យ សេវាឯកសារ និងស្រាវជ្រាវ និងកាលប្បវត្តិ ។ បញ្ហាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសមភាពរវាងភេទ បានប្រមូលផ្តុំវិស័យជាច្រើនដែលត្រូវជួយជាអាទិភាពមួយនៅក្នុងកម្មវិធីបណ្តុះបណ្តាល ព្រមទាំងសេវាពិគ្រោះយោបល់ ។ ការគាំទ្រដល់ការអភិវឌ្ឍរចនាសម្ព័ន្ធគ្របដណ្តប់ជាអាទិ៍ទៅលើប្រព័ន្ធសម្លេង ការថតសម្លេងទុក Audiovisuels និងការផ្សព្វផ្សាយតាមវិទ្យុអំពីសម័យប្រជុំពេញអង្គរបស់សភា សេវាបោះពុម្ព ការដឹកជញ្ជូន និងការជួសជុល ឬកសាងកន្លែងធ្វើការ ។

ការជួយខាងបច្ចេកទេសមានទម្រង់ផ្សេងៗដូចតទៅ៖ ការផ្តល់សេវាពិគ្រោះយោបល់ ការរៀបចំសិក្ខាសាលា ទស្សនកិច្ចសិក្សា ការទទួលជាបណ្តោះអាសន្ននូវបុគ្គលិក សេវាបណ្តុះបណ្តាលនៅនឹងកន្លែងធ្វើការ ការប្រជុំ និងសន្និសីទ ។

សូមកត់សម្គាល់ថា បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ គឺជាផ្នែកកាន់តែសំខាន់ឡើងនៅក្នុងកម្មវិធីជំនួយបច្ចេកទេស ។

**កំណត់សម្គាល់**

❋ ទំនាក់ទំនងអន្តរជាតិកំពុងរងគ្រោះដោយឱនភាពប្រជាធិបតេយ្យ ដែលត្រូវតែខិតខំបំពេញដោយការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សភានៅក្នុងកិច្ចការពិភពលោក និងតំបន់ ។

នៅក្នុងកម្រិតពិភពលោក សភាត្រូវខិតខំសហការជាមួយវេទិកា ឬអង្គការអន្តររដ្ឋាភិបាល ដោយរដ្ឋនីមួយៗត្រូវឈរលើសមភាព បង្កើតឡើងនូវកិច្ចព្រមព្រៀងទាំងឡាយដែលត្រូវយកមកអនុវត្តន៍នៅរដ្ឋរៀងៗខ្លួន ។

នៅក្នុងកម្រិតតំបន់ សភាត្រូវសម្របខ្លួនទៅនឹងស្ថានភាពថ្មី ដែលជាលទ្ធផលនៃការផ្ទេរអធិបតេយ្យភាពខ្លះ (គ្មានករណីបែបនេះទេនៅក្នុងកម្រិតអន្តរជាតិ) ជាគុណប្រយោជន៍ដល់ស្ថាប័នថ្មីរបស់តំបន់ ។

ជាមួយនឹងការខិតខំក្នុងកម្រិតជាតិ ត្រូវបន្ថែមនូវការចូលរួមអន្តរជាតិតាមរយៈសហប្រតិបត្តិការអន្តរសភាអន្តរជាតិ និងតំបន់ ។

## ៥-យុទ្ធសាស្ត្រអាទិភាពទី៥ : ការពង្រឹងពង្រីកមុខងារអភិវឌ្ឍស្ថាប័ន

### *៥.១-ការអភិវឌ្ឍធនធានមនុស្ស ដើម្បីព្រឹទ្ធសភាមានសេវាគាំទ្រប្រកបដោយគុណភាព*

-ដើម្បីអាចអនុវត្តមុខងារទាំងប្រាំ (មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ មុខងារតំណាង និងមុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍស្ថាប័ន) ឱ្យបានប្រកបដោយគុណភាព និងប្រសិទ្ធភាពពិតប្រាកដ ព្រឹទ្ធសភាត្រូវតែទទួលបាននូវសេវាគាំទ្រដ៏គាប់ប្រសើរពីអគ្គលេខាធិការដ្ឋាន ។ ក្រៅពីសេវាគាំទ្រផ្ទាល់ដល់មុខងារទាំង៥ខាងលើនេះ អគ្គលេខាធិការដ្ឋានត្រូវផ្តល់សេវាគាំទ្រផ្សេងៗទៀតដូចជា ការរៀបចំកំណត់បង្ហាញ ការធ្វើរបាយការណ៍ ការសង្ខេបរបាយការណ៍ ការស្រាវជ្រាវ ការរៀបចំឯកសារ ការរៀបចំកិច្ចប្រជុំគណៈកម្មការនានា គណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភា (សាមញ្ញ វិសាមញ្ញ) ការរៀបចំកម្មវិធីផ្សេងៗតាមភូមិភាគ ការបំពេញបេសកកម្មក្នុង/ក្រៅប្រទេស...។ល។ អាស្រ័យហេតុនេះ អគ្គលេខាធិការដ្ឋានគប្បីបន្តខិតខំជាអាទិភាពដូចតទៅ ៖

-ត្រូវយកចិត្តទុកដាក់បំពាក់មធ្យោបាយ និងធនធានបន្ថែមសមស្របព្រមទាំងទីកន្លែងធ្វើការឱ្យបានកាន់តែសមរម្យ ដើម្បីបង្កើនប្រសិទ្ធភាព និង

គុណភាពនៃសេវាគ្រប់ប្រភេទរបស់ព្រឹទ្ធសភា ។ ជាចម្បង ត្រូវយកចិត្តទុកដាក់ដល់ប្រព័ន្ធការពារសន្តិសុខ សុវត្ថិភាព ផាសុកភាព ព្រមទាំងបរិស្ថានឱ្យបានកាន់តែល្អថែមទៀត។

-មន្ត្រីរាជការព្រឹទ្ធសភា ត្រូវមានចំណេះដឹងខ្ពស់ សមត្ថភាពជំនាញ និងបច្ចេកវិទ្យា ព្រមទាំងភាសាបរទេសណាមួយច្បាស់លាស់។ ជាចាំបាច់ ត្រូវពិចារណារៀបចំឱ្យមានក្រុមឧត្តមទីប្រឹក្សា អ្នកជំនាញជាន់ខ្ពស់ខាងច្បាប់ នីតិវិធី ការស្រាវជ្រាវកិច្ចការសភា និងកិច្ចការអន្តរជាតិ ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះនៃប្រសិទ្ធភាព ប្រសិទ្ធផលសម្រាប់ការផ្តល់ពហុសេវា ដែលទាមទារសមត្ថភាពឯកទេសកាន់តែខ្ពស់ (តម្រូវការស្ថាប័ន តម្រូវការប្រទេស តម្រូវការសហប្រតិបត្តិការតំបន់ និងអន្តរជាតិ) ។

-ត្រូវបន្តយកចិត្តទុកដាក់វិនិយោគដល់ការធ្វើបច្ចុប្បន្នភាព និងបង្កើនសមត្ថភាពរបស់អគ្គនាយកដ្ឋានស្នូល ដែលមាននាយកដ្ឋានសំខាន់ៗជាសេនាធិការដូចជា នីតិវិធី ស្រាវជ្រាវច្បាប់ ស្រាវជ្រាវទូទៅ ស្រាវជ្រាវកិច្ចការសភា ស្រាវជ្រាវខាងថវិកា ស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិ លេខាធិការដ្ឋានអមគណៈកម្មការនានា នាយកដ្ឋានភូមិភាគ និងសមូហភាពដែនដី និងលេខាធិការដ្ឋានក្រុមទាំងឡាយ ។

-អគ្គនាយកដ្ឋានបម្រើ និងអគ្គនាយកដ្ឋានគាំទ្រ ត្រូវខិតខំអភិវឌ្ឍន៍សមត្ថភាពឱ្យខ្ពស់ ដើម្បីផ្តល់សេវាចាំបាច់ឱ្យបានកាន់តែល្អប្រសើរ និងទាន់ពេលវេលា ។

-ត្រូវបន្តបណ្តុះបណ្តាលជូនមន្ត្រីរាជការឱ្យមានវប្បធម៌មូលដ្ឋានក្នុងខ្លួនដូចជា វប្បធម៌នយោបាយ វប្បធម៌រដ្ឋបាល វប្បធម៌សភា វប្បធម៌ប្រជាធិបតេយ្យ

វប្បធម៌នីតិរដ្ឋ និងវប្បធម៌ជាតិ ។ ជាពិសេសត្រូវចេះនិយាយខ្មែរ សរសេរខ្មែរ និងប្រើប្រាស់ភាសាខ្មែរឱ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ខ្មែរ (ទាំងនិយាយ សរសេរ ទាំងការបកប្រែ) ។

-ត្រូវបន្តបណ្ដុះបណ្ដាលសមាជិកព្រឹទ្ធសភា និងជួរមន្ត្រីរាជការឱ្យចេះប្រើប្រាស់ដោយទូលំទូលាយក្នុងការងារប្រចាំថ្ងៃនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល ព្រមទាំងចេះបង្កើតកម្មវិធីសម្រាប់បំពេញតម្រូវការក្នុងប្រភេទសេវាចាំបាច់ របស់អង្គភាពរៀងៗខ្លួន ទាំងការដឹកនាំគ្រប់គ្រង និងការប្រាស្រ័យឆ្លើយឆ្លងជាសាធារណៈ ។

-ត្រូវបន្តបណ្ដុះបណ្ដាលជួរមន្ត្រីរាជការខាងរដ្ឋបាលឱ្យចេះស្ទាត់នូវជំនាញចាំបាច់ដូចជា លេខាធិការ រដ្ឋបាល ហិរញ្ញវត្ថុ គណនេយ្យ ការធ្វើផែនការ ការរៀបចំថវិកា និងគម្រោង ការធ្វើសារពើភ័ណ្ឌ អធិការកិច្ច និងសវនកម្ម ព្រមទាំងកំណែទម្រង់សាធារណៈលើគ្រប់វិស័យ ។

-ត្រូវបណ្ដុះបណ្ដាលជួរអ្នកគ្រប់គ្រងអំពីការគ្រប់គ្រងទូទៅ និងភាពជាអ្នកដឹកនាំ ការងារគ្រប់គ្រងរដ្ឋបាលសាធារណៈ ការគ្រប់គ្រងរដ្ឋបាលសភាទំនើប ការគ្រប់គ្រងធនធានមនុស្ស ការធ្វើផែនការរយៈពេលខ្លី មធ្យម វែង ការដោះស្រាយជម្លោះ ការងារជាក្រុម ការងារពិធីការ និងសហប្រតិបត្តិការអន្តរជាតិ... ។ល។

-ត្រូវបន្តបណ្ដុះបណ្ដាលជួរមន្ត្រីរាជការក្នុងអគ្គនាយកដ្ឋានស្ដូលអំពីការងារលេខាធិការ ការធ្វើកំណត់ហេតុសង្ខេប ពិស្ដារ ការសរសេរអត្ថបទព័ត៌មាន ការធ្វើបទសម្ភាសន៍ សេចក្ដីថ្លែងការណ៍ ការប្រើប្រាស់ជវលេខ ការងារទំនាក់ទំនងសាធារណៈ ការវិភាគច្បាប់ ស្ថិតិ និងទិន្នន័យ ការរៀបចំសុន្ទរកថា និងបទអន្តរាគមន៍...។

-ត្រូវបន្តបណ្តុះបណ្តាលមន្ត្រីរាជការអគ្គនាយកដ្ឋានបង្អែក អំពីការដឹកនាំ ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុ ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការធ្វើផែនការ ការសរសេររបាយការណ៍ ការងារសារពើភ័ណ្ឌ និងសំណង់ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងជំនាញចាំបាច់សម្រាប់ការផលិតសេវាជាក់ស្តែង។

-ត្រូវបន្តបណ្តុះបណ្តាលមន្ត្រីរាជការអគ្គនាយកដ្ឋានគាំទ្រលើការងារពិធីការ ទំនាក់ទំនងអន្តរជាតិ ទំនាក់ទំនងសាធារណៈ ការបោះពុម្ព ការផ្សព្វផ្សាយ ការងារព័ត៌មាន ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ការប្រើប្រាស់គេហទំព័រ Online Twitter, Facebook, E-mail... ការគ្រប់គ្រងបណ្ណាល័យ និងបណ្ណសារដ្ឋាន ។

-អគ្គលេខាធិការដ្ឋានត្រូវបន្តខិតខំស្រាវជ្រាវ និងកសាងគោលនយោបាយ និងកែលម្អបទដ្ឋាននៃការគ្រប់គ្រងរដ្ឋបាល គ្រប់គ្រងធនធានមនុស្សគ្រប់គ្រងហិរញ្ញវត្ថុតាមស្តង់ដារការងារនៃសភាទំនើប ព្រមទាំងខិតខំពង្រឹងសមត្ថភាពក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ អគ្គាធិការដ្ឋាន អង្គភាពលទ្ធកម្មសាធារណៈ អង្គភាពសវនកម្មផ្ទៃក្នុង អង្គភាពសវនកម្មបឋម នាយកដ្ឋានសំណង់ និងសារពើភ័ណ្ឌឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីបង្កើនជំនឿទុកចិត្ត និងភាពសុខដុមក្នុងស្ថាប័ន ។

### ៥.២-ការអភិវឌ្ឍវិស័យទំនាក់ទំនងសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពរបស់ព្រឹទ្ធសភា

-ការអភិវឌ្ឍបណ្ណាល័យ បណ្ណសារដ្ឋានព្រឹទ្ធសភាឱ្យទំនើប ដើម្បីបង្កើនសមត្ថភាព និងប្រសិទ្ធភាពនៃការស្រាវជ្រាវ ជាគុណប្រយោជន៍ដល់តម្រូវការព្រឹទ្ធសភា និងសាធារណជនផង ។ ការបោះពុម្ពមានចុះលេខកូដ ISBN

(International Standard Book Number) ការថែរក្សាឯកសាររបស់ព្រឹទ្ធសភាក្នុងបណ្ណសារដ្ឋាន ត្រូវមានការរៀបចំឱ្យបានហ្មត់ចត់តាមស្តង់ដារនៃជំនាញ និងបច្ចេកទេស ។

-ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាព័ត៌មានឱ្យមានទាំងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ទាំងការប្រើប្រាស់ប្រចាំថ្ងៃដោយសកម្ម និងមានប្រសិទ្ធភាព ក្នុងការងារគ្រប់វិស័យរបស់ស្ថាប័នផង ទាំងបម្រើដល់ការងារព័ត៌មាន ទំនាក់ទំនងអន្តរជាតិ និងទំនាក់ទំនងសាធារណៈផង ។

-បង្កើតយុទ្ធសាស្ត្រទំនាក់ទំនងសាធារណៈដ៏ទូលំទូលាយ តាមការផ្សព្វផ្សាយព័ត៌មានតាមពហុ Media, ប្រព័ន្ធ Website, បណ្តាញសង្គម (Social Networks), វិទ្យុ, ទូរទស្សន៍, កាសែត...។

- សិក្សា និងបង្កើតសារមន្ទីរព្រឹទ្ធសភា ដើម្បីបង្កើតឡើងនូវស្មារតី និងមរតកប្រជាធិបតេយ្យរបស់ជាតិ និងរដ្ឋ សម្រាប់បន្តវេនពីជំនាន់មុនទៅជំនាន់ក្រោយទៀត ។

-បង្កើនសមត្ថភាពរបស់ស្ទូឌីយោសម្រាប់ការផលិតផលិតផលសោតទស្សន៍ និងផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងប្រព័ន្ធឃោសនា ។

-ត្រូវខិតខំបង្កើនសមត្ថភាពទំនាក់ទំនង និងផលិតភាពនៃសេវារបស់នាយកដ្ឋានព័ត៌មាន ដើម្បីធ្វើជាសេនាធិការដល់ស្ថាប័នលើការងារទំនាក់ទំនងសាធារណៈជាមួយមហាជន ម្ចាស់ឆ្នោត ប្រព័ន្ធឃោសនា ក្រសួង ស្ថាប័ន សង្គមស៊ីវិល... ដើម្បីឱ្យគ្រប់មជ្ឈដ្ឋានខាងក្រៅយល់ដឹងដោយទូលំទូលាយ និងវិជ្ជមានអំពីព្រឹទ្ធសភា ហើយចេះមកទំនាក់ទំនងការងារជាមួយព្រឹទ្ធសភា ដោយស្មារតីស្ថាបនាពិតប្រាកដ ។

-គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម អគ្គលេខាធិការដ្ឋាន ត្រូវរក្សាទំនាក់ទំនងល្អជាមួយរាជរដ្ឋាភិបាល (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីទទួលបាននូវថវិកាប្រចាំឆ្នាំរបស់ស្ថាប័ន ក្នុងបរិមាណសមស្របទៅនឹងតម្រូវការនៃការអភិវឌ្ឍស្ថាប័នលើគ្រប់វិស័យ។

### ៥.៣-ការធានាគ្រប់គ្រងសន្តិសុខ សុវត្ថិភាព ផាសុកភាពព្រឹទ្ធសភាឱ្យបានពេញលេញ និងធានាការបើកចំហព្រឹទ្ធសភាជាសាធារណៈឱ្យមានលក្ខណៈគាប់ប្រសើរ

ក្នុងយុគសម័យបច្ចុប្បន្នដែលគំរាមកំហែងដោយអំពើភេរវកម្ម និងអសន្តិសុខ អស្ថេរភាពខាងបច្ចេកវិទ្យាព័ត៌មានពីសំណាក់ពួកភេរវករ និងឧក្រិដ្ឋជន (Hackers-Criminals) គប្បីកសាងព្រឹទ្ធសភាឱ្យមានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដែលបំពាក់ដោយកម្លាំងសន្តិសុខឯកទេស ប្រព័ន្ធបច្ចេកវិទ្យាខាងសន្តិសុខ និងប្រព័ន្ធបច្ចេកវិទ្យាខាងការប្រាស្រ័យឆ្លើយឆ្លងទំនើបទាន់សម័យ ។

ប្រការនេះទាមទារការរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងជាច្រើនដំណាក់កាល បន្ទាប់ពីការធ្វើការសិក្សាដោយល្អិតល្អន់អំពីការគំរាមកំហែងនានាមកលើស្ថាប័នព្រឹទ្ធសភា (Security Audit)។ ការវិនិយោគដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងបច្ចេកវិទ្យាដែលធានានូវស្តង់ដារខ្ពស់ខាងសន្តិសុខសុវត្ថិភាព ក្លាយជាកត្តាចាំបាច់ពុំអាចខ្វះបាន ។

ជាមួយនោះ ត្រូវកសាងបទដ្ឋាន និងស្តង់ដារសន្តិសុខ ដើម្បីបញ្ជ្រាបអប់រំ បណ្តុះបណ្តាលសមាជិកព្រឹទ្ធសភា មន្ត្រីបុគ្គលិក និងសាធារណៈជន ដើម្បីយល់អំពីសារសំខាន់នៃការថែរក្សាសន្តិសុខ សុវត្ថិភាពសម្រាប់ស្ថាប័ន ព្រឹទ្ធសភា និងដើម្បីធានាការបើកចំហជាសាធារណៈរបស់ស្ថាប័ននេះចំពោះសាធារណៈជនដែលជាម្ចាស់ (ទស្សនៈ សភាជាផ្ទះរបស់ប្រជាជន) ។

សន្តិសុខ សុវត្ថិភាព មិនត្រូវក្លាយជារបាំងសម្រាប់ការបើកចំហរបស់ព្រឹទ្ធសភាឡើយ ។

## VII-ហានិភ័យ

-ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេល១០ឆ្នាំ ដោយឡែក៥ឆ្នាំចុងក្រោយទាមទារនូវបរិបទ លក្ខខណ្ឌ សមត្ថភាព ធនធាន ធន្ធ: និងកិច្ចសហប្រតិបត្តិការដ៏ទូលំទូលាយពីគ្រប់តួអង្គសំខាន់ៗក្នុងព្រឹទ្ធសភា និងសង្គមជាតិ ព្រមទាំងសម្របទៅនឹងការវិវត្តក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោកផងដែរ ។

-ហានិភ័យខ្ពស់បណ្តាលមកពីជម្ងឺរាតត្បាត គ្រោះធម្មជាតិ អសន្តិសុខ និងការគំរាមកំហែងផ្សេងទៀតតែងមានផលប៉ះពាល់ដល់ដំណើរការការងាររបស់ព្រឹទ្ធសភាលើការបំពេញមុខងារទាំង៥ឱ្យបានរលូន ។ សភាពការណ៍តំបន់ និងពិភពលោកដែលប្រែប្រួលមិនទៀងទាត់ និងស្មុគស្មាញ រួមទាំងវិបត្តិសេដ្ឋកិច្ច និងពាណិជ្ជកម្មតែងជះឥទ្ធិពលអវិជ្ជមានមកលើកម្ពុជា ។

ផ្ទៃក្នុងព្រឹទ្ធសភាក៏ដូចជាផ្ទៃក្នុងជាតិ ទាមទារនូវការឯកភាពគ្នាខ្ពស់ ដើម្បីបង្កបរិយាកាសអនុគ្រោះប្រកបដោយសន្តិភាព សន្តិសុខ សុវត្ថិភាពពេញលេញដល់ដំណើរទៅមុខរបស់ព្រឹទ្ធសភា តាមគន្លងមហាវិថីនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ស្មារតីបង្រួបបង្រួមផ្សះផ្សាជាតិ និងស្តង់ដានៃសភាទំនើបពិតប្រាកដ ។

ភាពរលូន និងល្បឿននៃដំណើរការ ជារួមពឹងផ្អែកលើសមត្ថភាព និងធន្ធ:ដាច់ខាតរបស់ព្រឹទ្ធសភា ដើម្បីជម្នះលើឧបសគ្គ និងការលំបាកតូចធំទាំងឡាយដែលតែងតែកើតមាន ។ ចំណុចជាសារវ័ន្ត គឺការអភិវឌ្ឍជាតិមានសន្ទុះថ្មី ប្រកបដោយសក្តានុពល និងនិរន្តរភាព ។

## VIII-សេចក្តីសន្និដ្ឋាន

ការពង្រឹងសមត្ថភាពព្រឹទ្ធសភ. ាមក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលមានចែងខាងលើនេះ ជាការឆ្លើយតបនឹងយុទ្ធសាស្ត្ររួមរបស់កម្ពុជា ដែលយកអភិបាលកិច្ចល្អ និងនីតិរដ្ឋជាស្នូល ។ លើមូលដ្ឋានគ្រឹះនៃសមត្ថភាព និងធនធានជាសក្តានុពលដ៏ធំ ដែលព្រឹទ្ធសភាកសាងបានមកដល់បច្ចុប្បន្ននេះ ព្រមទាំងការប្តេជ្ញាចិត្ត ព្រឹទ្ធសភាកម្ពុជាកំពុងសម្លឹងមើលប្រកបដោយមហិច្ឆតា និងសុទិដ្ឋិនិយមខ្ពស់ លើមាគ៌ាដ៏វែងឆ្ងាយមាំឆ្ពោះទៅកាន់ស្តង់ដារការងារជាលក្ខន្តិកៈនៃសភាទំនើបលើសកលលោក ដើម្បីកាន់តែបំពេញបាននូវបេសកកម្មទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព ។

ចាប់ពីពេលនេះទៅមុខ ព្រឹទ្ធសភាត្រូវបន្តស្ថិតនៅលើការដ្ឋានមួយដ៏ធំ ដែលត្រូវប្រមូលផ្តុំការខិតខំដើម្បីសម្រេចឱ្យបានជោគជ័យជាជំហានៗ នូវផែនការសកម្មភាពទាំងឡាយដែលមានក្នុងយុទ្ធសាស្ត្រនេះ ។ ជោគជ័យនៃដំណាក់កាលមួយ នឹងបានជាកម្លាំងជំរុញឱ្យដំណាក់កាលបន្ទាប់ទទួលបានជោគជ័យថ្មី រហូតដល់សម្រេចបាននូវចក្ខុវិស័យសមតាមសេចក្តីសង្ឃឹម និងទំនុកចិត្តរបស់ប្រជាពលរដ្ឋកម្ពុជា ។ ជោគជ័យនៃដំណាក់កាលមួយអាចវាស់វែងបានតាមរយៈការកើនឡើងនូវប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រអាទិភាពទាំង៥ គឺៈ (១)ប្រសិទ្ធភាពនៃមុខងារនីតិកម្ម (២)ប្រសិទ្ធភាពនៃមុខងារតាមដានការអនុវត្តច្បាប់ (៣)ប្រសិទ្ធភាពនៃមុខងារតំណាង (៤)ប្រសិទ្ធភាពនៃមុខងារសហប្រតិបត្តិការអន្តរជាតិ និង(៥) ប្រសិទ្ធភាពនៃការអភិវឌ្ឍស្ថាប័ន ។

ព្រឹទ្ធសភាកម្ពុជាមានមោទនភាពលើសមិទ្ធផលដែលជាស្នាដៃនៃការខិតខំប្រឹងប្រែងរបស់សមាជិក សមាជិកាព្រឹទ្ធសភា គួបផ្សំនឹងកិច្ចសហប្រតិបត្តិការដ៏មានតម្លៃ និងមិនអាចខ្វះបានពីដៃគូអភិវឌ្ឍន៍ទាំងអស់។ អំណើះតទៅព្រឹទ្ធសភាកម្ពុជាប្តេជ្ញាបង្កើនកិច្ចសហប្រតិបត្តិការពហុរូបភាព និងពហុវិស័យ

តាមដែលអាចធ្វើទៅបាន ដើម្បីជំរុញការខិតខំពង្រឹងសមត្ថភាពព្រឹទ្ធសភាឱ្យបានពេញលេញ ។ ព្រឹទ្ធសភាមានជំនឿជឿជាក់យ៉ាងមាំថានឹងអាចបំពេញបាននូវបេសកកម្មប្រវត្តិសាស្ត្ររបស់ខ្លួន ដើម្បីចូលរួមកសាងកម្ពុជាជានីតិរដ្ឋនិងបរិយាប័ន្នពិតប្រាកដ ដែលលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិត្រូវបានចាក់ឫសយ៉ាងជ្រៅ ដំណើរការគ្រប់គ្រងរដ្ឋ គ្រប់គ្រងសង្គម គ្រប់គ្រងសេដ្ឋកិច្ចធានាបានតម្លាភាព និងគណនេយ្យភាពខ្ពស់ ។ ការអភិវឌ្ឍជាតិរលូន និងមាននិរន្តរភាព បរិស្ថានសង្គមប្រកបដោយយុត្តិធម៌និងភាពស្អាតស្អំ ។ ដំណើរការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋទទួលបានជោគជ័យយ៉ាងឆាប់រហ័ស ជាពិសេស ដំណើរការអនុវត្តជាប្រព័ន្ធនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ បានទទួលលទ្ធផលផ្លែផ្កាពិតប្រាកដជាគុណប្រយោជន៍ដល់ការអភិវឌ្ឍឃុំ សង្កាត់ លើគ្រប់វិស័យ ទាំង៨ភូមិភាគក្នុងក្របខ័ណ្ឌទូទាំងព្រះរាជាណាចក្រកម្ពុជា ។